# មេរៀនទី ៦ មនុស្សជាតិ៖ ប្រជានុរាស្ត្រនៃព្រះអាទិករ

មនុស្សមានចម្លើយជាច្រើនប្រភេទ ដើម្បីបកស្រាយពីប្រភពដើមរបស់មនុស្សជាតិ។ ទស្សនវិទូខំលើកហេតុផល អ្នកវិវត្តន៍និយមខំបង្ហាញសំណុំរឿងរបស់ពួកគេ អ្នកវិទ្យាសាស្ត្រធ្វើការប៉ាន់ស្មាន។ ការព្យាយាមរបស់អ្នកមិនជឿ ក្នុងការបកស្រាយអំពីប្រភពដើម និង ការអភិវឌ្ឍន៍របស់ពួកគេ បែរជាបន្សល់ត្រឹមតែភាពឥតន័យ ដ្បិតពួកគេជឿថា យើងគឺគ្រាន់តែជារឿងចៃដន្យមួយតែប៉ុណ្ណោះ ហើយគ្មានអត្ថន័យ និង គោលបំណងអ្វីនោះទេ។ ផ្ទុយទៅវិញ អ្នកនិពន្ធទំនុកតម្កើង បានធ្វើការផ្តេះបញ្ចាំងទៅលើដើមកំណើតរបស់គាត់ ហើយមានប្រសាសន៍ទូលទៅកាន់ព្រះជាម្ចាស់ថា "ទូលបង្គំសូមលើកតម្កើងព្រះអង្គ ដ្បិតទូលបង្គំជាស្នាព្រះហស្តដ៏ល្អអស្ចារ្យ ទូលបង្គំដឹងច្បាស់ថាអ្វីៗដែលព្រះអង្គធ្វើ សុទ្ធតែល្អអស្ចារ្យទាំងអស់...ព្រះអង្គក៏បានកំណត់ចំនួនថ្ងៃនៃអាយុជីវិតរបស់ទូលបង្គំទុកក្នុងបញ្ជីរបស់ព្រះអង្គមុននឹងថ្ងៃទាំងនោះមកដល់ទៅទៀត។ (គម្ពីរទំនុកតម្កើង ១៣៩:១៤,១៦) ។

យើងត្រូវបានបង្កើតឡើងឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់។ យើងត្រូវបានបង្កើតឡើង ដោយព្រះអាទិករនៃយើងដើម្បីគ្រប់គ្រងលើផែនដីនេះ ដោយភាពយុត្តិធម៌ ភាពថ្លៃប្រឌិត និង ដោយភាពទទួលខុសត្រូវ។ ទ្រង់បានប្រទានបញ្ញាញាណ អារម្មណ៍ និង សមត្ថភាពក្នុងការធ្វើការសម្រេចចិត្តប្រកបទំនួលខុសត្រូវខាងឯសីលធម៌។ យើងមានសមត្ថភាព សម្រេចកិច្ចការបានជាច្រើន ប៉ុន្តែយើងក៏មានឱកាសនឹងបំផ្លាញព្រះអំណោយទានពីធម្មជាតិរបស់យើង និង បដិសេធមិនទទួលស្គាល់អ្នកដែលបានប្រទានអំណោយទានទាំងអស់នោះមក ផងដែរ។ មធ្យោបាយតែមួយគត់ ដែលយើងអាចដឹងពីសក្តានុពល ដែលព្រះជាម្ចាស់បានប្រទានមក គឺតាមរយៈការស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ទ្រង់។ ប៉ុន្តែ ការមិនស្តាប់បង្គាប់របស់យើងបាន ទាញយើងចុះមិនឲ្យឈានទៅដល់សក្តានុពលរបស់យើងទាំងនៅក្នុងពេលបច្ចុប្បន្ន និង ដរាបអស់កល្បជានិច្ច។

នៅក្នុងមេរៀនមុន យើងបានសិក្សាអំពីស្ថានខាងឯវិញ្ញាណ។ ឥឡូវនេះយើងនឹងមើលទៅលើប្រជានុរាស្ត្រមួយប្រភេទទៀតរបស់ព្រះជាម្ចាស់៖ អម្បូរមនុស្ស។ នៅពេលដែលអ្នកសិក្សាមេរៀននេះ អ្នកអាចនឹងយល់អំពីខ្លួនអ្នកប្រសើរជាងមុន ហើយយល់កាន់តែច្បាស់ថែមទៀតពីអ្វីដែលជាតួនាទី ក៏ដូចជាសិទ្ធិរបស់អស់អ្នកទាំងឡាយណាដែលទទួលស្គាល់អធិបតីភាពរបស់ព្រះជាម្ចាស់។

## គម្រោងមេរៀន

ក. ដើមកំណើតរបស់មនុស្សជាតិ

ខ. និស្ស័យរបស់មនុស្សជាតិ

គ. ភាពអមតៈរបស់មនុស្សជាតិ

## វត្ថុបំណងមេរៀន

នៅពេលដែលយើងបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ផ្តល់នូវភស្តុតាងដែលថាមនុស្ស គឺជាស្នាព្រះហស្តដ៏ពិសេសរបស់ព្រះជាម្ចាស់។

២. រកឃើញបទគម្ពីរណាដែលបញ្ជាក់ ឬ បង្ហាញអំពីភាពដូចគ្នារបស់មនុស្ស ទៅនឹងព្រះជាម្ចាស់ នៅក្នុងបទគម្ពីរដែលយើងបានផ្តល់ជូន។

៣. ប្រើប្រាស់បទគម្ពីរ ដើម្បីធ្វើការពិភាក្សាអំពីទិដ្ឋភាពរូបី និង ទិដ្ឋភាពអរូបីរបស់មនុស្សជាតិ។

៤. បកស្រាយអំពីតួនាទីនៃមនសិការ និង ឆន្ទៈ ក្នុងការធ្វើការសម្រេចចិត្តយ៉ាងមានសីលធម៌។

៥. បកស្រាយគំនិតអំពីភាពអមតៈ និង អ្វីដែលកើតឡើងចំពោះមនុស្ស បន្ទាប់ពីគេបានស្លាប់ខាងឯរូបកាយហើយ។

## សកម្មភាពក្នុងការសិក្សា

១. ចូរអានគម្ពីរលោកុប្បត្តិ ១-៣ ទុកជាសេចក្តីផ្តើមសម្រាប់មេរៀននេះ។ លើសពីនេះទៅទៀត អ្នកត្រូវតែស្វែងរក និង អានបទគម្ពីរយោងនីមួយៗដែលបានផ្តល់ជូននៅក្នុងមេរៀន ពេលណាអ្នករៀនដល់បទគម្ពីរទាំងនោះ។

២. ចូរសិក្សាមេរៀនតាមធម្មតា។ នៅពេលដែលអ្នកបញ្ចប់មេរៀននេះ ចូរធ្វើការប្រឡងផ្ទាល់ខ្លួនឯង និងផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

## ពាក្យសំខាន់

| | | |
|---|---|---|
| មនសិការ | វិវត្តន៍ | អ្នកត្រួតពិនិត្យ |
| ដែលមានមនសិការ | ភាពអមតៈ | ភាពប្រហាក់ប្រហែលគ្នា |
| ផលវិបាក | ដែលមិនចេះខុស | មនុស្សក្រោមបង្គាប់ |

# ក. ដើមកំណើតរបស់មនុស្សជាតិ

## ស្នាព្រះហស្តដ៏ពិសេស

**វត្ថុបំណងទី១.** *ផ្តល់នូវភស្តុតាងដែលថាមនុស្ស គឺជាស្នាព្រះហស្តដ៏ពិសេសរបស់ព្រះជាម្ចាស់។*

ព្រះគម្ពីរបានថ្លែងយ៉ាងសមហេតុផល និង ត្រង់ៗទៅនឹងសំណួរដែលសួរថា៖ "តើមនុស្សជាតិកើតឡើងមកដោយរបៀបណា?" ព្រះគម្ពីរក៏បានផ្តល់នូវភស្តុតាងដែលស្តីអំពីដើមកំណើត គោលបំណង និង ជោគវាសនារបស់យើងផងដែរ។ ព្រះគម្ពីរបានបង្ហាញមកកាន់យើងថា យើងគឺជាស្នាព្រះហស្តដ៏ពិសេសរបស់ព្រះជាម្ចាស់។

មនុស្សមានឯកលក្ខណៈ(តែមួយ)។ ព្រះគម្ពីរបានថ្លែងថា ពូជមនុស្សគឺជាលទ្ធផលដែលបានមកពីកិច្ចការពិសេសរបស់ព្រះជាម្ចាស់៖ "រីឯព្រះអម្ចាស់ ជាព្រះដ៏វិសុទ្ធរបស់ជនជាតិអ៊ីស្រាអែល ជាព្រះដែលបានបង្កើតជនជាតិនេះមកទ្រង់មានព្រះបន្ទូលថា......យើងនេះហើយដែលបានបង្កើតផែនដី ព្រមទាំងបានបង្កើតមនុស្សអោយរស់នៅលើផែនដីនេះផង។" (គម្ពីរអេសាយ ៤៥:១១-១២) ។ បទគម្ពីរផ្សេងៗទៀតបានផ្តល់ឲ្យនូវទីបន្ទាល់ដូចគ្នានេះដែរ។

## *លំហាត់អនុវត្តន៍*

---

១ ចូរអានបទគម្ពីរ ហើយប្រាប់ពីអ្វីដែលបទគម្ពីរនីមួយៗប្រាប់យើងអំពីដើមកំណើតរបស់ពូជមនុស្សជាតិ។

- ក) គម្ពីរលោកុប្បត្តិ ១:២៧
- ខ) គម្ពីរលោកុប្បត្តិ ៥:១-២
- គ) គម្ពីរលោកុប្បត្តិ ៦:៧
- ឃ) គម្ពីរលោកុប្បត្តិ៩:៦
- ង) គម្ពីរទុតិយកថា ៤:៣២
- ច) គម្ពីរទំនុកតម្កើង ១០០:៣
- ឆ) គម្ពីរយ៉ាកុប ៣:៩

---

ការបង្កើតភាវៈទាំងប៉ុន្មានដទៃទៀត គឺគ្រាន់តែបានមកពីការបញ្ជារបស់ព្រះជាម្ចាស់ ដែលបានកើតឡើងភ្លាមៗប៉ុណ្ណោះ (សូមមើលនៅក្នុងគម្ពីរលោកុប្បត្តិ ១:២០,២៤) ប៉ុន្តែសម្រាប់ការបង្កើតមនុស្សវិញ ព្រះជាម្ចាស់បានធ្វើកិច្ចការពិសេសមួយ។ ដំបូងទ្រង់បានសូន្យ រូបបុរសម្នាក់ចេញពីសារធាតុដែលមាននៅក្នុងផែនដី បន្ទាប់មកទ្រង់បានផ្លុំបញ្ចូលខ្យល់ដង្ហើមនៃជីវិតចូលទៅក្នុងច្រមុះរបស់បុរសម្នាក់នោះ (គម្ពីរលោកុប្បត្តិ ២:៧) ហើយបុរសម្នាក់នោះក៏ក្លាយទៅជាភាវៈមានជីវិត។ *ការបញ្ចូលខ្យល់ដង្ហើមនៃព្រះជាម្ចាស់* នេះបានធ្វើឲ្យនិស្ស័យខាងឯវិញ្ញាណមួយ បានមកពីព្រះជាម្ចាស់ ក្លាយជាផ្នែកមួយនៃមនុស្ស ដែលបានផ្តល់ឲ្យគាត់នូវឋានៈមួយដែលខ្ពង់ខ្ពស់លើសភាវៈទាំងប៉ុន្មានផ្សេងទៀត ដែលមានរៀបរាប់នៅក្នុងគម្ពីរលោកុប្បត្តិ ជំពូក១។ លើសពីនេះទៅទៀត ការបញ្ជារបស់ព្រះជាម្ចាស់ ដែលឲ្យមនុស្សគ្រប់គ្រង និង

ត្រួតត្រាលើផែនដី បញ្ជាក់ពីគម្លាតដ៏ធំមួយរវាងមនុស្សពីរនាក់ដំបូង និង ភាវៈនៅលើផែនដីផ្សេងទៀត នៅក្នុងលំដាប់លំដោយនៃការបង្កើត។ (១:២៨)។

យើងក៏អាចឃើញពីការគាប់ព្រះហឫទ័យលើមនុស្សជាពិសេសមួយ នៅពេលដែលព្រះជាម្ចាស់ *ប្រទានពរ* ពួកគេ ឲ្យបានពោរពេញដោយផលផ្លែ (គម្ពីរលោកុប្បត្តិ១:២៨;៥:២) ដើម្បីឲ្យពួកគេអាចបង្កើតមនុស្ស ពាសពេញផែនដី និង *ផ្ដល់ឲ្យពួកគេនូវ អំណាចគ្រប់គ្រង* (ភាពជាអ្នកគ្រប់គ្រង) នៅលើភាវៈទាំងអស់ដែលមាននៅលើផែនដី និង គ្រប់ទាំងរុក្ខជាតិដែលមានគ្រប់ពូជទាំងអស់។

ភាពខុសគ្នាសំខាន់បំផុត រវាងមនុស្សមនុស្ស និង ភាវៈទាំងប៉ុន្មានផ្សេងទៀត គឺថា *មនុស្សគឺត្រូវបានបង្កើតឡើងឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់* (គម្ពីរលោកុប្បត្តិ ១:២៦) ។ គ្មានភាវៈណាផ្សេងទៀតដែលត្រូវបានបង្កើតឡើងឲ្យដូចជាព្រះជាម្ចាស់នោះទេ គឺមានតែមនុស្សប៉ុណ្ណោះដែលទទួលបានសណ្ឋានរបស់ព្រះអាទិករ។ យើងនឹងបានឃើញនៅក្នុងមេរៀនបន្ទាប់ ថាភាពដូចគ្នារបស់យើងទៅជាមួយព្រះជាម្ចាស់ គឺមិនមែនខាងឯរូបកាយនោះទេ ប៉ុន្តែគឺជាការដូចគ្នាខាងឯ*សីលធម៌* និង *វិញ្ញាណ*វិញ។

យើងបានរកឃើញភស្ដុតាងបន្ថែមទៀតអំពីនិស្ស័យពិសេសរបស់មនុស្ស នៅក្នុងភាពខុសគ្នាដែលយើងឃើញរវាងមនុស្ស និងសត្វ។ ចូរពិចារណាអំពីភាពខុសគ្នាខ្លះៗនៅក្នុងចំណោមភាពខុសគ្នាទាំងនេះ ៖

១. យើងមានអំណាចនៃការនិយាយ ដែលនោះគឺជាសមត្ថភាពដ៏អស្ចារ្យ ក្នុងការទំនាក់ទំនងគ្នា ទាំងនៅក្នុងគំនិតរូបី (ពិតជាក់ស្ដែង) និង គំនិតអរូបី (ទ្រឹស្ដី) តាមរបៀបប្រកបដោយភាពស្ទាត់ជំនាញ និង ភាពច្នៃប្រឌិត។ ឧទាហរណ៍មួយអំពីគំនិត*រូបី* (ពិតជាក់ស្ដែង) គឺ៖ "ខ្ញុំរស់នៅក្នុងផ្ទះពណ៌សមួយ ដែលមានប្រាំបន្ទប់។ ឧទាហរណ៍អំពីគំនិត*អរូបី* (ទ្រឹស្ដី) គឺ៖ "ការស្រឡាញ់គឺប្រសើរជាងការស្អប់"។ គំនិតទាំងពីរនេះ អាចយកទៅធ្វើទំនាក់ទំនងជាមួយនឹងមនុស្សដទៃទៀតបាន ព្រោះតែយើងមានសមត្ថភាពក្នុងការគិត យល់ និង បង្ហាញគំនិតរបស់យើងតាមរយៈពាក្យសំដី។ គ្មានសត្វណាផ្សេងទៀតអាចធ្វើយ៉ាងដូច្នេះបានឡើយ។

២. យើងមានសមត្ថភាពដើម្បីរីករាយជាមួយភាពស្រស់ស្អាត។ ប៉ុន្តែសត្វវិញ ហាក់បីដូចជាមិនដឹងពីតម្លៃនៃសួនច្បារដ៏ស្រស់ស្អាត លើសគំនរស្មៅដ៏អាក្រក់មួយនោះទេ។

៣. យើងមានសមត្ថភាពក្នុងការបែងចែករវាង ត្រូវ និង ខុស។ សត្វមិនមានសមត្ថភាពមួយនេះឡើយ។ ឧទាហរណ៍ សត្វឆ្កែមួយក្បាលអាចបង្ហាញឲ្យឃើញពីការមិនពេញចិត្ត នឹងការដាក់ទោសដោយសារតែវាបានមិនស្ដាប់បង្គាប់ ហើយវាអាចនឹងត្រូវបានម្ចាស់ដាក់កំហិត ឬ បង្ខឹកឲ្យស្ដាប់បង្គាប់ តាមរយៈការដាក់ទោសម្ដងហើយម្ដងទៀត ប៉ុន្តែវានៅតែមិនអាចដឹងថា ការដែលវាទៅលួចពងមាន់ ឬ ស៊ីកូនមាន់គឺជារឿងខុសឆ្គងខាងឯសីលធម៌នោះទេ។

៤. យើងដឹងច្បាស់ពីភាពចាំបាច់ ត្រូវថ្វាយបង្គំភាវៈដែលមានឋានៈខ្ពស់ជាងខ្លួន ប៉ុន្តែសត្វគ្មានទាំងសមត្ថភាពដើម្បីថ្វាយបង្គំ និងមធ្យោបាយក្នុងការសម្ដែងភាពគោរពយ៉ាងជ្រាលជ្រៅនេះទេ។

៥. យើងអាចដាក់ផែនការទុកមុន រៀបចំសម្រាប់ពេលអនាគត និង ធ្វើការផ្លាស់ប្ដូររឿងរ៉ាវផ្សេងៗ។ យើងរីករាយក្នុងការបង្កើតរចនាបទទីលំនៅថ្មី និង បែបបទសិល្បៈថ្មីៗ។ យើងរស់រានមានជីវិតជាបន្តបន្ទាប់ ដើម្បីកែច្នៃមជ្ឈដ្ឋានជុំវិញខ្លួនយើង ធ្វើឲ្យជីវិតកាន់តែមានភាពងាយស្រួល និង កាន់តែល្អប្រសើរឡើង។ ចំណែកសត្វវិញ គ្មានសមត្ថភាពក្នុងការច្នៃប្រឌិត និង មើលទៅថ្ងៃអនាគតបែបនេះបានឡើយ។ អ្វីៗដែលពួកវាធ្វើដើម្បីត្រៀមសម្រាប់ពេលមុខ គឺគ្រាន់តែជាការឆ្លើយតបទៅនឹងសភាវៈគតិរបស់វាប៉ុណ្ណោះ។ ឧទាហរណ៍ សត្វបក្សីមានសភាវៈគតិក្នុងការសាងសង់សំបុកសម្រាប់កូនៗរបស់ពួកវា ប៉ុន្តែជាច្រើនសតវត្សរ៍មកហើយ ពួកវានៅតែបន្តសាងសង់សំបុកដូចគ្នាទៅនឹងសំបុកដែលដូនតារបស់ពួកវាសាងសង់ដែរ។

ដូច្នេះហើយ វាបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ហើយថា មនុស្សគឺជាស្នាព្រះហស្តដ៏ពិសេសមួយរបស់ព្រះជាម្ចាស់។ យើងមិនមែនជារបស់ដែលកើតឡើងដោយចៃដន្យនោះទេ យើងមិនបាន "វិវត្តន៍" មកពីសត្វដែលតូចទាបនោះទេ។ យើងបានឃើញនៅក្នុងមេរៀនមុននេះ ថាព្រះជាម្ចាស់ដែលបានបង្កើតសាកលលោកមក ទ្រង់ក៏បានផ្គត់ផ្គង់ស្នាព្រះហស្តរបស់ទ្រង់ផងដែរ។ ធម្មជាតិដែលបណ្ដោយឲ្យនៅតែឯង មិនអាចអភិវឌ្ឍន៍ទៅមុខបានទេ មានតែបាត់បង់គុណភាពវិញ។ អ្វីគ្រប់យ៉ាងនឹងសឹករឹចរឹល។ ភាពមានសណ្ដាប់ធ្នាប់ ក៏ចាប់ផ្ដើមក្លាយទៅជាគ្មានសណ្ដាប់ធ្នាប់។ ដើម្បីរក្សារបស់ទាំងនេះ និង ធ្វើឲ្យវាបានកាន់តែល្អប្រសើរឡើង គឺចាំបាច់ត្រូវមានព្រះប្រាជ្ញាញាណ និង ថាមពលមកពីខាងក្រៅ ហើយខ្ពង់ខ្ពស់ជាអ្វីដែលមាននៅក្នុងប្រព័ន្ធមួយនោះ។ ដោយតាមរយៈកិច្ចការពិសេសនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ទើបធ្វើឲ្យមនុស្សដែលជាភាវៈដ៏អស្ចារ្យជាងគេនេះបានចាប់កំណើតឡើង។
(គម្ពីរកូឡូស ១:១៦-១៧)។

# លំហាត់អនុវត្តន៍

២ តើប្រយោគណាខ្លះនៅខាងក្រោមនេះ ផ្ដល់ភស្តុតាងដែលថាមនុស្សគឺជាស្នាព្រះហស្តដ៏ពិសេសមួយរបស់ព្រះជាម្ចាស់។

ក) ការបង្កើតមនុស្សគឺធ្វើទៅតាមរបៀបដូចគ្នា នឹងការបង្កើតរុក្ខជាតិ និង ជីវិតសត្វដែរ។

ខ) មានតែមនុស្សប៉ុណ្ណោះដែលបានទទួលជីវិត មកពីការផ្លុំខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់។

គ) មនុស្សទទួលបានអំណាចគ្រប់គ្រងលើជីវិតរុក្ខជាតិ និង សត្វ។

ឃ) មនុស្សត្រូវបានបង្កើតមកឲ្យមានសណ្ឋានដូចជាព្រះអាទិកររបស់ពួកគេ។

ង) មនុស្សគឺខុសពី ភាវៈផ្សេងទៀតនៅលើផែនដី ហើយថែមទាំងខ្ពង់ខ្ពស់ជាងភាវៈទាំងនេះផង។

ច) មានតែមនុស្សទេ ដែលមិនស្ថិតនៅក្រោមឫទ្ធានុភាពដែលខ្ពស់ជាងខ្លួន។

## បង្កើតមកឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់

**វត្ថុបំណងទី២.** *រកឃើញបទគម្ពីរណាដែលបញ្ជាក់ ឬ បង្ហាញអំពីភាពដូចគ្នារបស់មនុស្ស ទៅនឹងព្រះជាម្ចាស់ នៅក្នុងបទគម្ពីរដែលយើងបានផ្តល់ជូន។*

ព្រះគម្ពីរបង្រៀនយើងថាមនុស្ស គឺត្រូវបានបង្កើតឡើងឲ្យមានសណ្ឋាន ឬ ភាពដូចគ្នាទៅនឹងព្រះជាម្ចាស់ (គម្ពីរលោកុប្បត្តិ ១:២៦-២៧; ៥:១; ៩:៦ គម្ពីរ១កូរិនថូស ១១:៧ គម្ពីរយ៉ាកុប ៣:៩)។ យើងអាចគិតគូរ ដូចជាព្រះជាម្ចាស់ដែរ ទាក់ទងនឹងការរចនា និង គោលបំណងនៃរបស់អ្វីមួយ។ យើងរាល់គ្នា អាចបង្កើតរបស់ដែលមានប្រយោជន៍ និង ស្រស់ស្អាត ទៅតាមរបៀបរៀងៗខ្លួន។ យើងក៏អាចស្វែងរក គោលការណ៍នៅក្នុងការបង្កើតរបស់សព្វសារពើ ដែលបានផ្តល់ភស្តុតាងបន្ថែមទៅឲ្យកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ នៅក្នុងការសិក្សារបស់យើងផងដែរ។ តើនៅមានអ្វីទៀតដែលរាប់បញ្ចូលនៅក្នុង "លក្ខណៈដូចជាព្រះជាម្ចាស់" នេះ? តើលក្ខណៈមួយនេះ *មិនរាប់បញ្ចូល* អ្វីខ្លះ?

ពាក្យថា "នៅក្នុងសណ្ឋានដូចជាព្រះជាម្ចាស់" មិនមែនមានន័យថាមនុស្សគឺជាការចម្លងដូចបេះដាក់របស់ព្រះជាម្ចាស់នោះទេ។ ន័យរបស់ពាក្យនេះគឺថា មនុស្សយើងស្រដៀងទៅនឹងព្រះជាម្ចាស់ក្នុងរឿងខ្លះ។ យើងបានឃើញនៅក្នុងមេរៀនទី១រួចមកហើយ ថាព្រះជាម្ចាស់មិនអាចត្រូវបាននរណាមើលឃើញឡើយ ហើយទ្រង់គឺជាវិញ្ញាណ។ ដូច្នេះយើងដឹងថាសណ្ឋានរបស់ព្រះជាម្ចាស់នៅក្នុងយើងនោះ គឺ *មិនមែន* ជា *លក្ខណៈដូចខាងឯសាច់ឈាម* នោះទេ។ ប្រសិនបើលក្ខណៈដូចជាព្រះជាម្ចាស់របស់យើងនោះ មិនមែនខាងឯសាច់ឈាម តើជាអ្វីទៅ?

១. *បុគ្គលិកលក្ខណៈ។* ទោះបីជាព្រះជាម្ចាស់ជាវិញ្ញាណ វិញ្ញាណរបស់យើងរាល់គ្នាដែលជាមនុស្ស អាចទាក់ទងជាមួយព្រះវិញ្ញាណរបស់ទ្រង់បាន ព្រោះយើងក៏ជាភាវៈដែលមានលក្ខណៈភាពជាបុគ្គលដូចជាព្រះជាម្ចាស់ផងដែរ។ យើងអាចនឹងមានឱកាស ដើម្បីធ្វើទំនាក់ទំនងជាមួយទ្រង់បាន នៅក្នុងទំនាក់ទំនងជាបុគ្គលមួយ ហើយយើងក៏មានសមត្ថភាពក្នុងការមានទំនាក់ទំនងជាមួយភាវៈដទៃផ្សេងទៀតដូចជាព្រះជាម្ចាស់ដែរ។

២. *លក្ខណៈដូចខាងឯសីលធម៌។* យើងក៏មានសមត្ថភាពដើម្បីធ្វើការបែងចែករវាងល្អ និង អាក្រក់ដូចជាព្រះជាម្ចាស់ដែរ។ ដើមឡើយ បុគ្គលិកលក្ខណៈទាំងស្រុងរបស់មនុស្ស មានដូចជា សតិបញ្ញា អារម្មណ៍ និង ឆន្ទៈ គឺចង្អុលទៅកាន់ព្រះជាម្ចាស់ដោយផ្ទាល់។ និស្ស័យខាងឯសីលធម៌របស់មនុស្ស គឺជាការចម្លងមួយដែលមានដែនកំណត់ ចេញពីនិស្ស័យខាងឯសីលធម៌ដ៏គ្មានដែនកំណត់របស់ព្រះជាម្ចាស់។ មនុស្សមានសេរីភាពក្នុងការធ្វើការជ្រើសរើស និង ធ្វើអ្វីៗប្រកបដោយការទទួលខុសត្រូវ។ មនុស្សអាចសាកល្បង ប្រើប្រាស់ វិនិច្ឆ័យ អភិវឌ្ឍន៍ និង រីកចម្រើន នៅពេលដែលគេប្រើប្រាស់សេរីភាពរបស់ពួកគេដើម្បីជ្រើសរើសរវាង ល្អ និង អាក្រក់។ ការពិត គឺថាមនុស្សក៏ដឹងខ្លួនច្បាស់ អំពីការចាំបាច់ត្រូវជ្រើសរើសរវាងត្រូវ និង ខុស។

៣. *និស្ស័យដែលប្រកបដោយវិចារណញ្ញាណ* យើងមានលក្ខណៈដូចទៅនឹងវិចារណញ្ញាណរបស់ព្រះជាម្ចាស់ ព្រោះតែនិស្ស័យដែលប្រកបដោយវិចារណញ្ញាណ ឬ សតិបញ្ញារបស់យើង សមត្ថភាពរបស់យើងក្នុងការញែកហេតុផល និង ការស្គាល់ព្រះជាម្ចាស់ ព្រមទាំងរឿងជាច្រើនផ្សេងទៀត។ សមត្ថភាពនេះក៏ អាចត្រូវបានចាត់ទុកថា ជាលក្ខណៈដូចខាងឯគំនិតរបស់យើង នឹងព្រះដែលបានបង្កើតយើងផងដែរ។

៤. *សមត្ថភាពគ្រប់គ្រង* ។ យើងរាល់គ្នាដូចជាព្រះជាម្ចាស់ ត្រង់សមត្ថភាពប្រើប្រាស់ក្នុងការប្រើប្រាស់អំណាចត្រួតត្រា និងការគ្រប់គ្រងលើអ្វីមួយ។ យើងអាចផ្សាំងសត្វដែលមានកម្លាំងខ្លាំងជាងយើង ។ យើងអាចគ្រប់គ្រងទន្លេដោយសាងសងទំនប់ ដើម្បីផលិតបានជាអគ្គីសនី។ យើងធ្វើឲ្យវាលខ្សាច់ មានផ្ការីកលូតលាស់ដូចនៅក្នុងតំបន់មានជីវជាតិដូចធម្មជាតិ។ សមត្ថភាពដែលព្រះជាម្ចាស់បានប្រទានមកនេះ គឺជាការឆ្លុះបញ្ចាំងតាមរបៀបតូចតាចមួយ អំពីអំណាចត្រួតត្រារបស់ព្រះជាម្ចាស់ នៅលើសាកលលោកទាំងមូល។

៥. ភាពយល់ច្បាស់ពីខ្លួនឯង។ ក្នុងនាមជាភាវៈមានភាពជាបុគ្គល ដែលត្រូវបានបង្កើតឡើងឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់ យើងទាំងអស់គ្នាមានការដឹងអំពីខ្លួនឯង។ តាំងពីពេលដំបូងនៅក្នុងជីវិត កុមារចាប់ផ្តើមទទួលអារម្មណ៍ថា ពួកគេគឺផ្សេងពី មនុស្សគ្រប់គ្នានៅក្នុងក្រុមគ្រួសាររបស់គេ។ ពួកគេគឺមានតែខ្លួនឯង។  មិនថាគ្រួសាររបស់គេតម្រូវឲ្យធ្វើអ្វី មិនថាវប្បធម៌នៅជុំវិញក៏ពួកគេដឹងថា ពួកគេគឺដាច់ដោយឡែក។ ពួកគេមានក្តីសុបិន្ត មហិចតា ក្តីសង្ឃឹម ភាពភ័យខ្លាច និង បំណងចិត្តផ្ទាល់ខ្លួន។ ពួកគេមិនដូចភាវៈដទៃផ្សេងទៀតទេ។ សត្វទាំងឡាយផ្សេងទៀត មិនមានភាពយល់ច្បាស់ពីខ្លួនឯងនេះទេ។

៦. *និស្ស័យខាងឯសង្គម។* មូលដ្ឋានគ្រឹះនៃនិស្ស័យខាងឯសង្គមរបស់ព្រះជាម្ចាស់ គឺមេត្រីភាពរបស់ព្រះជាម្ចាស់ ឬ សេចក្តីស្រឡាញ់របស់ទ្រង់។ នៅក្នុងភាពអស់កល្បជានិច្ច ព្រះជាម្ចាស់បានរកឃើញគោលបំណងនៃសេចក្តីស្រឡាញ់របស់ទ្រង់នៅក្នុងព្រះត្រៃឯក។ ព្រះយេស៊ូបានមានព្រះបន្ទូលថា៖ "ខ្ញុំបានស្រឡាញ់អ្នករាល់គ្នា ដូចព្រះបិតាស្រឡាញ់ខ្ញុំដែរ។ ចូរទុកសេចក្តីស្រឡាញ់របស់ខ្ញុំអោយស្ថិតនៅជាប់នឹងអ្នករាល់គ្នាចុះ... ចូរអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។" (គម្ពីរយ៉ូហាន១៥:៩,១២)។ ដោយយើងបានទទួលនិស្ស័យខាងឯសង្គមមួយនេះ យើងស្វែងរកទំនាក់ទំនងជាមួយព្រះជាម្ចាស់ និង អ្នកដទៃផ្សេងទៀត ព្រមទាំងបានរៀបចំជីវិតដោយយោងទៅតាម ក្រុមសង្គមដំបូងគេបង្អស់មួយ៖ គ្រួសាររបស់យើង។ សេចក្តីស្រឡាញ់ និង ចំណាប់អារម្មណ៍របស់យើងលើអ្នកដទៃ បានមកផ្ទាល់ពីផ្នែកសង្គមនៃនិស្ស័យរបស់យើងនេះហើយ។

## លំហាត់អនុវត្តន៍

៣ ចូរស្វែងរកខគម្ពីរខាងក្រោមនេះ ហើយប្រាប់ពីភាពដូចគ្នារបស់មនុស្សទៅជាមួយនឹងព្រះជាម្ចាស់ ដែលមាននៅក្នុងខគម្ពីរនីមួយៗ។

ក) គម្ពីរលោកុប្បត្តិ ២:១៨

ខ) គម្ពីរអេភេសូ ៤:២៤

គ) គម្ពីរកូឡុស ៣:១០

ឃ) គម្ពីរទំនុកតម្កើង ១៣៩:១៣-១៦

ង) គម្ពីររ៉ូម ១០:៨-១១

ច) គម្ពីរលោកុប្បត្តិ ១:២៦,២៨

ឆ) គម្ពីរ១ពេត្រុស ១:១៥

ព្រះគម្ពីរបានផ្តល់យើងឲ្យនូវដំណើររឿងដ៏សមហេតុផលមួយ អំពីដើមកំណើតរបស់មនុស្ស។ ដំណើររឿងទាំងនេះ និយាយអំពីនិស្ស័យ និង សក្តានុភាពដែលព្រះបង្កើតមកជាមួយពួកមនុស្ស។ រឿងទាំងនេះក៏បានបង្ហាញការពិតអំពីភាពដូចគ្នារបស់យើងទៅនឹងព្រះអាទិកររបស់យើង ។ រឿងនេះជួយយើងឲ្យបានឃើញថាតើ យើងពិសេស និង ខ្ពង់ខ្ពស់កម្រិតណា បើធៀបជាមួយសត្វផ្សេងៗទៀត។ព្រះគម្ពីរក៏បានបង្រៀនយើងថា រួមជាមួយនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់យើងដែលជាភាវៈដែលមានសីលធម៌ យើងមានទំនួលខុសត្រូវ យ៉ាងសំខាន់ខ្លះៗ ជាទំនួលខុសត្រូវដែលជះឥទ្ធិពលលើជោគវាសនាអស់កល្បជានិច្ចរបស់យើង ដែលយើងនឹងធ្វើការសិក្សានៅក្នុងមេរៀនបន្ទាប់ទៀតនេះ។

# ខ. និស្ស័យរបស់មនុស្សជាតិ

**វត្ថុបំណងទី៣.** *ប្រើប្រាស់បទគម្ពីរ ដើម្បីធ្វើការពិភាក្សាអំពីទិដ្ឋភាពរូបី និង ទិដ្ឋភាពអរូបីរបស់មនុស្សជាតិ។*

ប្រសិនបើយើងមានការយល់ដឹងបានពេញលេញជាងនេះ អំពីនិស្ស័យរបស់មនុស្ស នោះនឹងមានភាពងាយស្រួលសម្រាប់យើងដោះស្រាយបញ្ហា និង យល់ពីរបៀប និង មូលហេតុដែលយើងប្រព្រឹត្តិអំពើដូចដែលយើងបានធ្វើ ។ ជារឿងពិតណាស់ ដែលថាមនុស្សគឺជាស្នាព្រះហស្តដ៏ស្មុគស្មាញមួយ មនុស្សមានរូបកាយមួយដ៏គួរឲ្យស្ញប់ស្ញែង មានគំនិតដែលចេះគិតច្រើន និង សមត្ថភាពក្នុងបែងចែករវាងត្រូវ និង ខុស។ ទាំងនេះគឺគ្រាន់តែជាលក្ខណសម្បត្តិ ដ៏លេចធ្លោមួយចំនួនតូចរបស់យើងតែប៉ុណ្ណោះ។ ការរៀបរាប់នេះ បង្ហាញមកកាន់យើងថាយើងមានទិដ្ឋភាព*រូបី* ឬ *រូបកាយ*ដែលអាចមើលឃើញ និង *ទិដ្ឋភាពអរូបី* ឬ គ្មានរូបកាយ ដែលមិនអាចមើលឃើញ មិនអាចវាស់វែង ឬ វិភាគនៅក្នុងមន្ទីរពិសោធន៍បានឡើយ។ ឥឡូវនេះសូមពិចារណាអំពីទិដ្ឋភាព ឬ លក្ខណសម្បត្តិផ្សេងៗទាំងនេះនៃនិស្ស័យរបស់មនុស្ស។

# ទិដ្ឋភាពរូបី

វាគឺជារឿងងាយស្រួលសម្រាប់យើង ក្នុងការសំគាល់ពីទិដ្ឋភាពរូបី ឬ រូបកាយ របស់មនុស្សជាតិ។ វាគឺជាអ្វីដែលយើងមើលឃើញនៅក្នុងបុគ្គលម្នាក់ទៀត។ វាគឺជាអ្វីដែល គ្រូពេទ្យអាចធ្វើការពិនិត្យ និង ធ្វើការវះកាត់បាន។ វាជាអ្វីដែលអាចថ្លឹង វាស់វែង និង វិភាគនៅក្នុងមន្ទីរពិសោធន៍បាន។ វានោះហើយគឺជាខ្លួនប្រាណរបស់មនុស្ស។

បទគម្ពីរបាននិយាយអំពីខ្លួនប្រាណជាញឹកញាប់ ហើយបានរួមបញ្ចូលនៅក្នុងការប្រោសលោះរបស់យើងផងដែរ (គម្ពីររ៉ូម ៨:២៣ គម្ពីរ១កូរិនថូស ៦:១២-២០)។ តើព្រះគម្ពីរបានផ្តល់តម្លៃអ្វី ទៅឲ្យខ្លួនប្រាណរបស់មនុស្ស? ស្របពេលដែលយើងទទួលបានការបង្រៀនថា ទិដ្ឋភាពដែលគ្មានរូបរបស់មនុស្ស គឺសំខាន់ខ្លាំងជាងខាងរូបកាយ (គម្ពីរម៉ាថាយ ១០:២៨) យើងក៏មិនត្រូវគិតថាខ្លួនប្រាណរបស់យើង គឺជាអ្វីដែលគួរឲ្យស្អប់ខ្ពើម និង អាក្រក់ជាប់នៅជាមួយយើងនោះដែរ។ ផ្ទុយទៅវិញ លោកសាវ័កប៉ុលបានបង្រៀនថា ទោះបីជាខ្លួនប្រាណរបស់យើងត្រូវផុយរលួយបន្ទាប់ការស្លាប់ហើយក៏ដោយ រូបកាយរបស់យើងនឹងត្រូវប្រោសឲ្យមានរស់ឡើងវិញយ៉ាងអស្ចារ្យនៅថ្ងៃណាមួយជាក់ជាមិនខាន ៖ "ព្រះអម្ចាស់យេស៊ូគ្រិស្ត.......... ព្រះអង្គនឹងបំផ្លាស់បំប្រែរូបកាយដ៏ថោកទាបរបស់យើងនេះ អោយបានដូចព្រះកាយ ប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ" (គម្ពីរភីលីព ៣:២០-២១)។

នៅក្នុងសំណេរទៅកាន់ក្រុមជំនុំក្រុងកូរិនថូស លោកប៉ុលប្រាប់ថា រូបកាយរបស់អ្នកជឿ គឺជាសមាជិកនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។ លោកបានមានប្រសាសន៍ថា៖ រូបកាយរបស់ពួកគេគឺដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ដោយសារមូលហេតុនេះហើយ បានដាក់ទំនួលខុសត្រូវឲ្យគ្រិស្តបរិស័ទ ដើម្បីសរសើរតម្កើងព្រះជាម្ចាស់ជាមួយនឹងរូបកាយរបស់គេ (គម្ពីរ១កូរិនថូស ៦:១៥, ១៩-២០)។

ព្រះអម្ចាស់យេស៊ូបានលើកតម្កើងតម្លៃរូបកាយមនុស្ស យ៉ាងខ្ពស់បំផុត នៅពេលដែលទ្រង់បានចាប់កំណើតយករូបកាយជាមនុស្សដោយផ្ទាល់ព្រះអង្គ។ លោកលូកាបានកត់ត្រាថា ព្រះយេស៊ូបានរីកលូតលាស់មាឌ នៅពេលដែលទ្រង់មានវ័យចម្រើនឡើង (គម្ពីរលូកា ២:៤០) ។ ជាការពិត អ្នកសរសេរសំបុត្រផ្ញើទៅសាសន៍ហេប្រឺ បានប្រកាសថា វាគឺជារឿង*ចាំបាច់*មួយ ដែលព្រះអម្ចាស់នៃយើងត្រូវមានរូបកាយមួយ ដើម្បីឲ្យទ្រង់អាចជាបូជាចារ្យជាន់ខ្ពស់ដែលប្រកបដោយចិត្តអាណិតអាសូរដល់យើង និង ជាព្រះសង្គ្រោះដែលបានរំដោះបាបយើង (គម្ពីរហេប្រឺ ២:១៤-១៥,១៧-១៨)។

# លំហាត់អនុវត្តន៍

៤ ចូរផ្គូផ្គងបទគម្ពីរយោង (ខាងស្ដាំ) ទៅជាមួយនឹងសេចក្ដីរៀបរាប់ដែលត្រឹមត្រូវ (ខាងឆ្វេង)។

.........ក) រូបកាយរបស់មនុស្សគឺជាស្នាព្រះហស្ត ដ៏អស្ចារ្យមួយរបស់ព្រះជាម្ចាស់ ដែលទ្រង់បានមានព្រះបន្ទូលប្រកាសថា ល្អប្រសើរណាស់។

........ខ) ដោយសារតែព្រះយេស៊ូមានរូបកាយជាមនុស្ស ទ្រង់អាចធ្វើជាបូជាចារ្យជាន់ខ្ពស់ ដែលប្រកបដោយចិត្តអាណិតអាសូររបស់យើងបាន។

.........គ) រូបកាយជាមនុស្សរបស់យើង និង ទិដ្ឋភាពផ្សេងក្នុងរូបកាយនោះ គឺត្រូវបានប្រើប្រាស់ជាគំរូមួយសម្រាប់តំណាងឲ្យព្រះកាយរបស់ព្រះគ្រិស្ដ។

.........ឃ) រូបកាយត្រូវតែទទួលបានការលើកតម្កើងជាដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

.........ង) រូបកាយជាមនុស្សរបស់យើងរាល់គ្នាក៏ត្រូវបានរួមបញ្ចូលទៅក្នុងការប្រោសលោះរបស់យើងផងដែរ។

.........ច) រូបកាយរបស់យើង ត្រូវយកទៅប្រើប្រាស់នៅក្នុងការបម្រើដ៏វិសុទ្ធ និង សមរម្យដល់ព្រះជាម្ចាស់។

.........ឆ) រូបកាយជាមនុស្សរបស់យើង នឹងត្រូវបានប្រោសឲ្យរស់ឡើងវិញ និង កែប្រែឲ្យក្លាយជាដូចព្រះកាយដែលប្រកបដោយសិរីរុងរឿងរបស់ព្រះយេស៊ូ។

១) គម្ពីរលោកុប្បត្តិ ១:២៧,៣១
២) គម្ពីររ៉ូម១២:១
៣) គម្ពីរ១កូរិនថូស៦:១៥,១៩-២០
៤) គម្ពីរទំនុកតម្កើង១៣៩:១៣-១៦
៥) គម្ពីរហេប្រឺ ២:១៤-១៥,១៧-១៨
៦) គម្ពីរ១កូរិនថូស ៦:១៤
៧) គម្ពីរភីលីព ៣:២០-២១
៨) គម្ពីររ៉ូម៨:២៣
៩) គម្ពីរ១កូរិនថូស ១២:១២-២៧

## ទដ្ឋិភាពអរូបី ( គ្មានរូប)

ការស្គាល់ពីទដ្ឋិភាពរូបីរបស់យើងគឺមានភាពងាយស្រួលណាស់ តែវាគឺជារឿងពិបាកមួយក្នុងការរៀបរាប់អំពីអ្វីដែលបង្កើតបានជាខ្នាតនៃទដ្ឋិភាពអរូបី (គ្មានរូប)។ ឧទាហរណ៍ ព្រះគម្ពីរបានថ្លែងអំពី *ព្រលឹង* និង *វិញ្ញាណ* នៅក្នុងគម្ពីរ១ថេស្សាឡូនិក ៥:២៣ ដែលរួមជាមួយរូបកាយ បង្កើតបានទៅជាបុគ្គលពេញលក្ខណៈមួយរូប។ ទោះជាយ៉ាងណាក្តី នៅក្នុងគម្ពីរម៉ាថាយ ១០:២៨ ព្រលឹងហាក់បីដូចជា តំណាងឲ្យទដ្ឋិភាពអរូបីទាំងមូលរបស់យើងតែម្តង។ តើយើងគឺជាភាវៈដែលជាទិដ្ឋភាពពីរ ឬ ជាភាវៈដែលជាទិដ្ឋភាពបី? តើព្រលឹង និង វិញ្ញាណគឺជារបស់តែមួយឬ ខុសពីគ្នា?

ជារឿងដ៏ពិបាកខ្លាំងណាស់ ក្នុងការកំណត់ថាតើ*ព្រលឹង* ឬ *វិញ្ញាណ* គឺជាទដ្ឋិភាពពីរផ្សេងគ្នានៃភាវៈទាំងមូលរបស់យើង ឬ តែមួយ និង ជារបស់ដូចគ្នា។ សូមចំណាំការនេះការយកចិត្តរបស់យើង នៅពេលដែលយើងសិក្សាឲ្យបានកាន់តែលំអិតជាងនេះទៀត អំពីធាតុផ្សំដែលគ្មានរូបរបស់យើង។

អ្នកប្រាជ្ញខាងព្រះគម្ពីរខ្លះ ជឿថានៅពេលដែលព្រះជាម្ចាស់ បានបង្កើតមនុស្សដំបូង ទ្រង់បានផ្លុំខ្យល់ដង្ហើមតែមួយគត់ទៅក្នុងគាត់គឺ៖ ព្រលឹងដ៏រស់។ អ្នកប្រាជ្ញខាងព្រះគម្ពីរខ្លះទៀត ជឿថាទិដ្ឋភាពអរូបីនៃខ្លួនរបស់យើង មានធាតុផ្សំពីរប្រភេទ។ ធាតុផ្សំមួយគឺ *ព្រលឹង* ដែលជាគោលការណ៍នៃជីវិត*ជីវសាស្ត្រ* ឬ ដែលផ្តល់ឲ្យយើងនូវដង្ហើម និង ធ្វើឲ្យយើងក្លាយជាភាវៈមានជីវិត។ ចំណែកធាតុផ្សំមួយទៀតគឺ *វិញ្ញាណ* ដែលជាមូលដ្ឋានគ្រឹះនៃជីវិត ប្រកបដោយ*សនិទានភាព* (ការរិះគិតពិចារណា) ឬ ជាអ្វីដែលទាក់ទងនឹងការពិចារណា ឬ ការយល់ដឹង។

## *លំហាត់អនុវត្តន៍*

---

៥ ចូរអានខគម្ពីរខាងក្រោម ហើយប្រាប់ថាតើខគម្ពីរទាំងនេះ បានបញ្ជាក់អំពីទិដ្ឋភាពអរូបីមួយ ឬ ពីររបស់ផងមនុស្ស៖

- ក) គម្ពីរលោកុប្បត្តិ ២:៧
- ខ) គម្ពីរទំនុកតម្កើង ៤២:៦
- គ) គម្ពីរ១កូរិនថូស ៥:៣
- ឃ) គម្ពីរហេព្រើ ៤:១២
- ង) គម្ពីរ១ថេស្សាឡូនិក ៥:២៣

---

ជីវិតប្រកបដោយសនិទានភាព មានធាតុផ្សំជាច្រើន។ យើងនឹងបានឃើញថា ធាតុផ្សំបីយ៉ាងដំបូងក៏ជាទដ្ឋិភាពនៃបុគ្គលិកលក្ខណៈផងដែរ។ ធាតុផ្សំទាំងបីយ៉ាងនោះមានដូចខាងក្រោម៖

១. *ធាតុផ្សំខាងឯសតិបញ្ញា ៖* សមត្ថភាពដើម្បីយល់ដឹង ដើម្បីពិចារណា និង ដើម្បីចងចាំ។

២. *ធាតុផ្សំខាងឯអារម្មណ៍ ៖* សមត្ថភាពដើម្បីទទួលអារម្មណ៍ ក្នុងការទទួលរងនូវឥទ្ធិពលពីអ្វីដែលអ្នកនោះស្គាល់ ឬ ឆ្លងកាត់។

៣. *ឆន្ទៈ* ៖ សមត្ថភាពដើម្បីជ្រើសរើស ដើម្បីសម្រេចចិត្ត និង ធ្វើសកម្មភាព។

៤. *មនសិការ* ៖ ចំណេះដឹងអំពីខ្លួនឯង ទាក់ទងទៅនឹងខ្នាតគំរូអំពីរឿងត្រឹមត្រូវ និង រឿងខុស ដែលគេបានស្គាល់រួចមកហើយ។

នៅក្នុងការសិក្សារបស់យើង អំពីនិស្ស័យរបស់ព្រះជាម្ចាស់ (មេរៀនទី១) យើងបានដឹងថា យើងត្រូវបានបង្កើតមកជាមួយនឹងគ្រឿងផ្សំជាមូលដ្ឋាននៃបុគ្គលិកលក្ខណៈដែលមានដូចជា៖ សតិបញ្ញា អារម្មណ៍ និង ឆន្ទៈ។ លក្ខណៈទាំងនេះ ជួយឲ្យយើងអាចមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ និង ជាមួយមនុស្សដទៃទៀតតាមរបៀបប្រកបដោយទំនួលខុសត្រូវ និង មានអត្ថន័យ។ ធាតុផ្សំដែលគ្មានរូបទាំងនេះ រួមជាមួយនឹងជីវិតខាងឯសាច់ឈាមរបស់យើង ជួយឲ្យយើងអាចរស់នៅជាជីវិតពេញលេញ និង គ្រប់គ្រាន់។ យើងបានបង្ក្រាបបរិស្ថាននៅជុំវិញយើង ហើយដាក់យកអ្វីដែលចាំបាច់សម្រាប់មានជីវិតរស់ពីក្នុងបរិស្ថាននោះ។ យើងរៀនធ្វើការជាមួយអ្នកដទៃនៅក្នុងបរិយាកាសសង្គមមួយដ៏ស៊ីសង្វាក់គ្នា។ យើងព្យាយាមយ៉ាងខ្លាំងបំផុត ដើម្បីផ្គាប់ព្រះហឫទ័យព្រះអាទិកររបស់យើង ដែលបានប្រទានអ្វីៗគ្រប់យ៉ាងដែលចាំបាច់សម្រាប់ជីវិតដ៏មានន័យ និង ការសង្គ្រោះដ៏អស់កល្បជានិច្ច។

*ឆន្ទៈ* របស់យើង និង *មនសិការ* របស់យើងគឺជាធាតុផ្សំដ៏មានសារៈសំខាន់នៃទដ្ឋិភាពខាងឯសីលធម៌នៃជីវិតអរូបីរបស់យើង ដែលយើងនឹងបានឃើញនៅក្នុងចំណុចបន្ទាប់ទៀតនៅក្នុងការសិក្សារបស់យើងនេះ។

## លំហាត់អនុវត្តន៍

៦ ដោយយោងទៅតាមការពិភាក្សាខាងលើ យើងអាចដឹងយ៉ាងច្បាស់ថា

ក) យើងទាំងអស់គ្នា ផ្សំឡើងចេញពីធាតុផ្សំបីយ៉ាង៖ ខ្លួនប្រាណ ព្រលឹង និង វិញ្ញាណ។

ខ) ព្រះគម្ពីរបានបង្រៀនយ៉ាងច្បាស់ៗ ថាមនុស្សគឺជាភាវៈដែលមានបីចំណែក។

គ) យើងត្រូវបានបង្កើតឡើងដោយធាតុផ្សំពីរយ៉ាង៖ ខ្លួនប្រាណ និង ព្រលឹង។

ឃ) ព្រះគម្ពីរបានបង្រៀនយ៉ាងច្បាស់ៗថា មនុស្សគឺជាភាវៈដែលមានពីរចំណែក

ង) បទគម្ពីរបានថ្លែងអំពី ខ្លួនប្រាណ ព្រលឹង វិញ្ញាណ ដង្ហើមនៃជីវិត និង ពាក្យជាច្រើនផ្សេងទៀត ដើម្បីធ្វើការរៀបរាប់អំពីនិស្ស័យរបស់យើង ប៉ុន្តែមិនបានបង្ហាញឲ្យបានច្បាស់ៗ ថាតើយើងមាននិស្ស័យពីរចំណែក ឬក៏បីចំណែក។

៧ ធាតុផ្សំទាំងបួនយ៉ាងនៃជីវិតប្រកបដោយសនិទានភាព របស់មនុស្សលោកគឺមាន

............................................................ ........................................................

............................................................ ........................................................

# ទដ្ឋិភាពខាងឯសីលធម៌

**វត្ថុបំណងទី៤.** *បកស្រាយអំពីតួនាទីនៃមនសិការ និង ឆន្ទៈ ក្នុងការធ្វើការសម្រេចចិត្តយ៉ាងមានសីលធម៌។*

លក្ខណៈប្រកបដោយសនិទានភាព នៃជីវិតអរូបីរបស់យើង ដែលយើងទើបតែនឹងបានសិក្សារួចមកហើយ បានត្រៀមដើម្បីសម្រាប់សកម្មភាពត្រឹមត្រូវ ឬ ខុស។ សតិបញ្ញារបស់យើង ជួយឲ្យយើងដឹងពីបញ្ហាត្រូវ និង ខុស។ អារម្មណ៍របស់យើង បានជំរុញឲ្យយើងធ្វើដំណើរទៅតាមទិសដៅមួយ ឬ មួយផ្សេងទៀត ហើយឆន្ទៈរបស់យើងជាអ្នកសម្រេចរឿងនោះ។ ប៉ុន្តែបើគ្មានមនសិការរបស់យើងដែលជាធាតុផ្សំទីបួនទេ នោះនឹងមិនអាចមានសកម្មភាពដែលប្រកបដោយសីលធម៌បានឡើយ។

មនសិការរបស់យើងអាច ត្រូវបានគេហៅថា "សម្លេងមកពីខាងក្នុង" ដែលដាក់ក្រឹត្យវិន័យខាងឯសីលធម៌របស់ព្រះជាម្ចាស់ មកក្នុងយើងទៅតាមសកម្មភាពជាក់លាក់ណាមួយ ហើយជំរុញឲ្យយើងស្តាប់បង្គាប់ក្រឹត្យវិន័យនោះ។ ដើម្បីស្វែងយល់ឲ្យបានកាន់តែច្បាស់អំពី លក្ខណៈនៃអំណាចខាងឯសីលធម៌មួយនេះ យើងត្រូវពិចារណាអំពី*មនសិការ* និង *ឆន្ទៈ* ដ្បិតទាំងនេះគឺមានទាក់ទងនឹងទង្វើរបស់យើង។

## មនសិការ

យើងឃើញយ៉ាងខ្លីៗរួចមកហើយថា មនសិការរបស់យើងគឺទាក់ទងជាមួយនឹង ឥរិយាបថ និង សកម្មភាពរបស់យើង។ មនសិការគឺជាញាណសតិដែលជួយឲ្យយើងធ្វើការវិនិច្ឆ័យបានយ៉ាងសមរម្យរវាងការធ្វើសកម្មភាព ឬ ការបង្កើតបានឥរិយាបថដែលនាំឲ្យព្រះជាម្ចាស់គាប់ព្រះហឫទ័យ ឬ មិនគាប់ព្រះហឫទ័យ។ ព្រះជាម្ចាស់បានបើកបង្ហាញនៅក្នុងព្រះបន្ទូលរបស់ទ្រង់ អំពីខ្នាតគំរូនៃការនៅរស់នៅដ៏សមស្របមួយ។ សេចក្តីបង្រៀន និង ការអនុវត្តន៍ជាក់ស្តែងនៃសេចក្តីពិតដ៏វិសុទ្ធ ដែលយើងទទួលបាន ជួយឲ្យយល់ពីរបៀបដែលយើងគួរតែរស់នៅ។ ដូច្នេះ អ្វីដែលយើងដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដូចដែលបានបើកបង្ហាញនៅក្នុងព្រះបន្ទូលរបស់ទ្រង់ និង អ្វីដែលបានដឹងនៅក្នុងការអនុវត្តន៍តាមសេចក្តីពិតមួយនេះ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង បង្កើតបានជាមូលដ្ឋានគ្រឹះដែលមនសិការអាចធ្វើសកម្មភាពបាន។

មនសិការត្រួតពិនិត្យ (ព្រមានអំពី ឬ ណែនាំអំពី) ភាពត្រឹមត្រូវ និង ភាពមិនត្រឹមត្រូវ នៅក្នុងឥរិយាបថដែលយើងរៀបនឹងស្តែងចេញមក ឬ ធ្វើសកម្មភាពចេញមក។ លោកសាវ័កប៉ូលបានផ្តល់នូវឧទាហរណ៍មួយអំពីរឿងនេះ នៅពេលដែលលោកមានប្រសាសន៍ទៅកាន់អស់អ្នកដែល "បង្ហាញអោយឃើញថា កិច្ចការដែលគម្ពីរវិន័យចែងទុកអោយធ្វើនោះ មានចារឹកនៅក្នុងដួងចិត្តរបស់គេស្រាប់ហើយ។ មនសិការរបស់គេ ព្រមទាំងការរិះគិតរបស់គេ ដែលនាំអោយមានការចោទប្រកាន់ខ្លួន ឬដោះសាខ្លួន ក៏ផ្តល់សក្ខីភាពអំពីការនេះដែរ។" (គម្ពីររ៉ូម២:១៥)

ឧទាហរណ៍ សូមគិតពីអ្នកជំនួញគ្រិស្តបរិស័ទម្នាក់ ឈ្មោះចឺរ៉ូម ដែលគាត់បានប្រឈមមុខជាមួយនឹងការសម្រេចចិត្តយ៉ាងដូច្នេះថា៖ "តើខ្ញុំគួរតែទៅញ៉ាំអាហារពេលល្ងាចនៅជាមួយដៃគូជំនួញដ៏សំខាន់ម្នាក់ នៅកន្លែងមួយដែលមានការកំសាន្តអាក្រក់ៗដែរឬទេ? ឬមួយខ្ញុំគួរប្រកាន់ភ្ជាប់លើគោលជំហររបស់ខ្ញុំ

ដែលថានេះគឺជារឿងមិនត្រឹមត្រូវ ទោះបីជាខ្ញុំអាចនឹងបាត់បង់កិច្ចសហប្រតិបត្តិការណ៍ជំនួញមួយនេះ ប្រសិនបើខ្ញុំមិនទទួលការអញ្ជើញមួយនេះ?

ខ្នាតគំរូរបស់ចឺរ៉ូមគឺព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គាត់ដឹងថា ព្រះជាម្ចាស់បានមានព្រះបន្ទូលអំពីការសេពគប់មិនត្រឹមត្រូវ (គម្ពីរ២កូរិនថូស ៧:១ គម្ពីរ១កូរិនថូស ១៥:៣៣)។ មនសិការរបស់គាត់*បញ្ជាក់* ថាការទទួលយកការអញ្ជើញនោះគឺជារឿងមិនត្រឹមត្រូវនោះទេ ព្រោះវាផ្ទុយពីខ្នាតគំរូរបស់ព្រះជាម្ចាស់។ មនសិការរបស់គាត់ក៏ *រំឭក* គាត់ពីកាតព្វកិច្ចរបស់ដែលត្រូវសម្ដែងអាកប្បកិរិយតាមអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។ ដូច្នេះ មនសិការរបស់ចឺរ៉ូមប្រកាន់ (សំគាល់ពីភាពខុស ) រវាងសកម្មភាពត្រឹមត្រូវ និង សកម្មភាពមិនត្រឹមត្រូវដោយផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដោយសារតែចឺរ៉ូមគឺជាគ្រិស្តបរិស័ទម្នាក់ មនសិការរបស់គាត់និយាយទៅកាន់គាត់ ដោយមានការចូលរួមពីព្រះវិញ្ញាណដ៏វិសុទ្ធ។

ប្រសិនបើចឺរ៉ូមមិនយកចិត្តទុកដាក់អំពីសក្ដីភាពនៃមនសិការ និង ទំនួសខុសត្រូវខាងឯសីលធម៌របស់គាត់នោះទេ គាត់នឹងមានអារម្មណ៍ថា អាម៉ាស់ និង ស្ដាយក្រោយ ហើយនឹងមានភាពភ័យខ្លាចចំពោះផលពិបាកនៃសកម្មភាពរបស់គេ។ ការចុះញ៉ុមជាមួយសេចក្ដីល្បួង នាំមកនូវអារម្មណ៍បរាជ័យភាពបរាជ័យក្នុងការរស់នៅតាមខ្នាតគំរូរបស់ព្រះជាម្ចាស់។ អារម្មណ៍ដែលមានទាក់ទងនឹងភាពបរាជ័យគឺភាពអាម៉ាស់ ភាពស្ដាយក្រោយ និង ភាពភ័យខ្លាច មិនមែនជាធាតុផ្សំនៃមនសិការនោះទេ ប៉ុន្តែជាអារម្មណ៍តែប៉ុណ្ណោះ។ ដូច្នេះ មនសិការដើរតួជាអ្នកវិនិច្ឆ័យឥរិយាបថខាងឯគំនិត និង អាកប្បកិរិយារបស់យើង។

## *លំហាត់អនុវត្តន៍*

៨ ចំពោះគ្រិស្តបរិស័ទម្នាក់ ការមិនស្ដាប់បង្គាប់តាមមនសិការ នាំឲ្យមានអារម្មណ៍បីយ៉ាងកើតឡើងរួមមាន.........................................................................................................................

ដោយព្រះជាម្ចាស់បានបង្កើតយើងមកជាមួយនឹងអ្នកត្រួតពិនិត្យ ឬ "សម្លេង" នៅខាងក្នុងនេះ យើងគួរតែស្វែងយល់បន្ថែមទៀតអំពីអ្វីដែលធ្វើបានចំពោះមនសិការរបស់យើង និង អ្វីដែលជាដែនកំណត់នៃមនសិការ។ ទីមួយ មនសិការក៏អភិវឌ្ឍន៍នៅពេលយើងលូតលាស់ និង ពេញវ័យ ដូចជាសតិបញ្ញាដែរ។ នៅពេលដែលបានយល់ពីទំនួលខុសត្រូវរបស់យើង យើងក៏ចាប់ផ្ដើមយល់ពីផលពិបាកនៃសកម្មភាពរបស់យើងផងដែរ។ ទីពីរ ព្រះគម្ពីរបង្រៀនថា មនសិការក៏អាចសៅហ្មង ពុករលួយ និង ធ្វើឲ្យអស់ខ្លឹមសារបានដែរៈ

> អ្នកខ្លះនៅតែជំពាក់ចិត្តនឹងព្រះក្លែងក្លាយនៅឡើយ គេបរិភោគសាច់ទាំងនោះទុកដូចជាសំណែន ហើយដោយគេរិះគិតមិនបានដិតដល់ ក៏នឹកស្មានថា ខ្លួនត្រូវសៅហ្មង។
> (គម្ពីរ១កូរិនថូស៨:៧)
>
> ចំពោះអ្នកដែលមានចិត្តបរិសុទ្ធ អ្វីៗទាំងអស់សុទ្ធតែបរិសុទ្ធ រីឯអ្នកដែលមានចិត្តសៅហ្មង និងមិនជឿអ្វីៗទាំងអស់សុទ្ធតែមិនបរិសុទ្ធ ព្រោះ*ប្រាជ្ញា និងមនសិការរបស់គេសុទ្ធតែសៅហ្មង*។
> (គម្ពីរទីតុស១:១៥)។

គេចាញ់បោកពុតត្បុតរបស់មេបោកប្រាស់។ *មនសិការរបស់អ្នកទាំងនោះជាប់ជាខ្ញុំបំរើរបស់អារក្ស* ។ (គម្ពីរ១ធីម៉ូថេ ៤:២) ។

បទគម្ពីរទាំងនេះបានបញ្ជាក់ថា ភាពឆ្វេសប្រហែសនៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ ការប្រងើយកន្តើយនឹងសម្លេងរបស់មនសិការ និង ការបោះបង់ជំនឿ អាចធ្វើឲ្យបាត់បង់ប្រសិទ្ធិភាពរបស់ឆន្ទៈដែលជាមុខងារព្រះជាម្ចាស់ប្រទានឲ្យ។ ទោះជាយ៉ាងណាក្តី ព្រះគម្ពីរមិនបង្ហាញថា មនសិការអាចនឹងបំផ្លាញបាននោះទេ។

ទីបី មនសិការគឺមិនមែន*មិនចេះខុស* (គ្មានកំហុស មានតែភាពឥតខ្ចោះ) នោះទេ ។ នោះមានន័យថា មនសិការអាចនាំមនុស្សម្នាក់ឲ្យដើរខុសផ្លូវ ប្រសិនបើយកខ្នាតគំរូមិនត្រឹមត្រូវមកប្រើ។ មុនពេលមានហេតុការណ៍អាក្រក់កើតឡើងចំពោះលោកសាវ័កប៉ូលនៅតាមផ្លូវទៅក្រុងដាម៉ាស់ លោកសាវ័កប៉ូល ពិតជាមានភាពប្រាកដប្រជាចំពោះឥរិយាបថខុសឆ្គងរបស់គាត់ខ្លាំងណាស់។ លោកបាន*គិតថាលោកកំពុងតែធ្វើរឿងដែលត្រឹមត្រូវហើយ។* ចិត្តខ្នះខ្នែង និង ឥរិយាបថដ៏សុក្រិតរបស់លោក គឺសុទ្ធតែអាចបញ្ជាបាន ប៉ុន្តែសកម្មភាពរបស់លោក គឺពិតជាគួរឲ្យគម្រក់ខ្លាំងណាស់! ព្រោះតែការពិចារណារបស់លោក ទទួលយកការបកស្រាយមួយដែលមិនត្រឹមត្រូវចេញពីគម្ពីរសម្ព័ន្ធមេត្រីចាស់ មនសិការបានមើលឃើញតែពីការបកស្រាយនោះ ហើយវាក៏នាំលោកឲ្យវង្វេង ។ (គម្ពីរកិច្ចការ ៩)។

ដូច្នេះ មនសិការរបស់យើង វិនិច្ឆ័យសកម្មភាព និង ឥរិយាបថរបស់យើងដោយផ្អែកលើមូលដ្ឋាននេះ៖

១. ចំណេះដឹងរបស់យើងអំពីអត្ថិភាពរបស់ព្រះជាម្ចាស់។
២. បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលបានបើកបង្ហាញ។
៣. ការយល់ដឹងខាងឯសីលធម៌ ដែលព្រះជាម្ចាស់បានប្រទានមក។
៤. អ្វីដែលយើងទទួលបានពីការបង្រៀន (អ្វីដែលដាក់ចូលទៅក្នុងមនសិការ)
៥. ខ្នាតគំរូសង្គម ដែលយើងបានទទួលយក។

យើងដឹងថា ចំពោះព្រះជាម្ចាស់យើងប្រកបដោយទំនួលខុសត្រូវ។ ទោះជាយ៉ាងណា ខ្នាតគំរូសង្គមមិននៅដដែលរហូតនោះទេ ដោយព្រោះតែអំពើបាប និង ការបដិសេធ ខ្នាតគំរូរបស់ព្រះជាម្ចាស់។ ដូច្នេះខ្នាតគំរូតែមួយគត់នៃមនសិការ ដែលព្រះជាម្ចាស់សព្វព្រះទ័យគឺជាខ្នាតគំរូផ្អែកលើព្រះបន្ទូលរបស់ទ្រង់ដែលត្រូវបកស្រាយដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

## លំហាត់អនុវត្តន៍

៩ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ។

ក) មនសិការប្រាប់យើង ថាតើយើងកំពុងរស់យ៉ាងមានទំនួលខុសត្រូវស្របទៅតាម ខ្នាតគំរូដ៏សមរម្យមួយដែរឬទេ។

ខ) គ្រិស្តបរិស័ទ តែងតែត្រូវបានដឹកនាំដោយខ្នាតគំរូសង្គម នៅក្នុងការកំណត់ថាអ្វីត្រូវ ឬអ្វីដែលខុស។

គ) មនសិការគឺតែងតែស្របតាមខ្នាតគំរូដែលវាផ្អែកលើ។

ឃ) ប្រសិនបើមនសិការផ្អែកលើខ្នាតគំរូនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះវាមិនអាចសៅហ្មង ពុករលួយ និង ធ្វើឲ្យអស់ខ្លឹមសារនោះទេ។

ង) មនសិការរបស់គ្រិស្តបរិស័ទម្នាក់គឺ កំណត់ដោយការបកស្រាយរបស់គាត់អំពីសកម្មភាពត្រូវ និង ខុស។

ច) មនសិការអាចទៅជាសៅហ្មង ខូចបង់ និង បាត់បង់ខ្លឹមសារ ប្រសិនបើវានៅតែត្រូវបានគេប្រងើយកន្តើយ។

ឆ) មនសិការរបស់មនុស្សម្នាក់អាចនឹងត្រូវបំផ្លាញ ប្រសិនបើអ្នកនោះ នៅតែបន្តធ្វើសកម្មភាពតាមរបៀបដែលផ្ទុយពីមនសិការរបស់គាត់បានប្រាប់។

---

**ឆន្ទៈ**

ឆន្ទៈគឺជាញាណសតិរបស់យើងក្នុងការជ្រើសរើស ឬ ធ្វើការសម្រេចចិត្ត រវាងសកម្មភាពទាំងឡាយណាដែលអាចកើតមានឡើង។ និយាយអំពីសកម្មភាពដែលអាចកើតមានឡើង យើងត្រូវស្គាល់វាឲ្យច្បាស់មុនពេលដែលយើងបង្ហាញអារម្មណ៍របស់យើងទៅចំពោះសកម្មភាពទាំងអស់នោះ។ បន្ទាប់មកដោយផ្អែកលើចំណេះដឹង នឹង អារម្មណ៍ យើងអាចជ្រើសរើសសកម្មភាពជាក់លាក់ណាមួយតាមរយៈសកម្មភាពនៃឆន្ទៈរបស់យើង។ យើងអាចជ្រើសរើសបានដោយសេរី ដើម្បីធ្វើអ្វីដែលស្របទៅជាមួយនឹងនិស្ស័យរបស់យើង ។ យើងអាចមានឆន្ទៈក្នុងការរត់បាន ប៉ុន្តែយើងមិនអាចមានឆន្ទៈក្នុងការរស់នៅក្នុងទឹកដូចជាត្រីបាននោះទេ។ ការរត់នោះគឺ ស្របទៅតាមនិស្ស័យរបស់យើង ឯការរស់នៅក្នុងទឹកគឺមិនស្របនឹងនិស្ស័យរបស់យើងនោះទេ។ ដូចដែលយើងនឹងបានឃើញនៅក្នុងមេរៀនបន្ទាប់របស់យើងថា យើងត្រូវឃាត់ឃាំងឲ្យមានកំណត់ដោយសារតែអំពើបាប ដូច្នេះហើយ យើងមិនអាចផ្លាស់ប្តូរ ស្ថានភាពខាងឯសីលធម៌របស់យើងបានដោយគ្រាន់តែ *មានឆន្ទៈ* ដើម្បីក្លាយជាសុចរិតនោះទេ។

ចុះតើអ្វីទៅដែលមានឥទ្ធិពលនៅលើឆន្ទៈ? តើឆន្ទៈស្ថិតនៅក្រោមការគ្រប់គ្រងរបស់យើងទាំងស្រុង ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ តើមានដំណើរការអ្វីខ្លះ ដែលចូលរួមនៅក្នុងការធ្វើការសម្រេចចិត្តរបស់យើង? ចូរយើងពិនិត្យទៅលើបញ្ហាទាំងនេះ ស្របពេលដែលយើងសិក្សាអំពីនិស្ស័យបានកាន់តែច្បាស់ថែមទៀត។

នៅពេលដែលព្រះជាម្ចាស់បានបង្កើតមនុស្សមក ទ្រង់បានប្រទានអំណាចនៃការជ្រើសរើស៖ ជាអំណាចក្នុងការជ្រើសរើសប្រព្រឹត្តិបាប ឬ មិនប្រព្រឹត្តិបាប។ ព្រះជាម្ចាស់បានដាក់មនុស្សនៅក្នុងសួនអេដែន ហើយដាក់លក្ខខ័ណ្ឌដើម្បីឲ្យលោកអាចនឹងបន្តប្រកបជាមួយទ្រង់បន្តទៅទៀត៖ "ព្រះជាអម្ចាស់បានបញ្ជាមនុស្សដូចតទៅ៖ «អ្នកអាចបរិភោគផ្លែឈើទាំងប៉ុន្មាន នៅក្នុងសួនឧទ្យាននេះបាន តែមិនត្រូវបរិភោគផ្លែឈើពីដើម ដែលនាំអោយស្គាល់ល្អស្គាល់អាក្រក់ឡើយ ដ្បិតថ្ងៃណាអ្នកបរិភោគផ្លែនោះ អ្នកមុខជាស្លាប់មិនខាន»។" (គម្ពីរលោកុប្បត្តិ ២:១៦-១៧)

តើលោកអដាំ បានឆ្លើយតបទៅនឹងការណែនាំមកពីព្រះជាអម្ចាស់នេះយ៉ាងដូចម្តេច? ដំណើរការនៃការធ្វើការសម្រេចចិត្តប្រហែលជាដើរទៅតាមលំនាំដូចខាងក្រោមនេះ៖

១. *បញ្ញាញាណ* របស់លោកអដាំស្របទៅតាមខ្នាតគំរូរបស់ព្រះជាម្ចាស់។ លោកបានយល់ពីអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលប្រាប់មកលោក។
២. *អារម្មណ៍* របស់គាត់ស្របទៅតាមភាពសុចរិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់មានសិទ្ធិក្នុងការបង្កើតខ្នាតគំរូនេះឡើង ព្រោះទ្រង់គឺជាព្រះអាទិករ និង ព្រះអម្ចាស់ជាព្រះអធិបតីរបស់លោក។
៣. *ឆន្ទៈ* របស់លោកបានរៀបចំដើម្បីធ្វើការសម្រេចចិត្តជ្រើសរើសរវាង ការទទួលយក និង ការច្រានចោលការល្បួងដែលសត្វពស់បានបង្ហាញលោក។ (គម្ពីរលោកុប្បត្តិ ៣:៤-៦)។
៤. នៅក្នុងពេលវេលាដ៏សំខាន់នេះ មនសិការរបស់លោកអដាំបានលំអៀងទៅរកផលវិបាកនៃការធ្វើផ្ទុយពីខ្នាតគំរូរបស់ព្រះជាម្ចាស់។
៥. លោកអដាំ បានចុះញ៉មនឹងសេចក្តីល្បួង ដោយ*សកម្មភាពនៃឆន្ទៈរបស់លោក*។

ដូច្នេះ លោកអដាំមានចេតនា មិនស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង ទទួលរងទុក្ខពីផលវិបាកនោះភ្លាមៗតែម្តង។ មនសិការរបស់លោកផ្តន្ទាទោសលោក ធ្វើឲ្យលោកដឹងថា លោកបានបរាជ័យក្នុងការគោរពតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។ លោកបានមានអារម្មណ៍អាម៉ាស់ ស្តាយក្រោយ និង ភ័យខ្លាច ព្រោះទង្វើមិនស្តាប់បង្គាប់របស់លោកបានបំផ្លាញភាពត្រឹមត្រូវរបស់លោក (គម្ពីរលោកុប្បត្តិ ៣:៧-១០) ។ ពេលនេះនិស្ស័យរបស់លោកក៏ត្រូវសៅហ្មង។ លោកបានធ្លាក់ចុះពីភាពត្រឹមត្រូវគ្មានទោសអ្វី ទៅក្នុងភាពសៅហ្មង។ តាំងពីការធ្លាក់ចុះរបស់លោកអដាំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់មក យើងក៏ត្រូវបានកំណត់ដោយនិស្ស័យបាបរបស់យើង។ យើងមិនអាច *មានឆន្ទៈ* ស្តាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយគ្មានការជួយពីព្រះជាម្ចាស់បាននោះឡើយ។ លោកប៉ូលមានប្រសាសន៍ថា៖ "ដ្បិតខ្ញុំដឹងថា អ្វីៗដែលល្អមិនស្ថិតនៅក្នុងខ្ញុំទេ ពោលគឺមិនស្ថិតនៅក្នុងខ្ញុំដែលមាននិស្ស័យលោកីយ៍ទេ។ ខ្ញុំមានឆន្ទៈនឹងធ្វើអំពើល្អ តែខ្ញុំគ្មានសមត្ថភាពនឹងប្រព្រឹត្តអំពើល្អបានឡើយ។" (គម្ពីររ៉ូម ៧:១៨)។

ទោះជាយ៉ាងណាព្រះជាម្ចាស់ មិនគាប់ព្រះហឫទ័យនឹងទុកមនុស្សឲ្យស្ថិតនៅក្នុងភាពសៅហ្មងរបស់គេនោះដែរ។ ទ្រង់បានលាតសន្ធឹងព្រះគុណរបស់ទ្រង់ ទៅកាន់មនុស្សនៅក្នុងស្ថានភាពបាត់បង់របស់ពួកគេ ទ្រង់អំពាវនាវទៅកាន់ពួកគេដើម្បីឲ្យពួកគេលន់តួបាបរបស់ពួកគេ ហើយទទួលយកសេចក្តីសង្គ្រោះដែលទ្រង់ប្រទានឲ្យ (គម្ពីរទីតុស ២:១១) ។ នៅត្រង់នេះហើយ ដែលព្រះវិញ្ញាណដ៏វិសុទ្ធបានចាប់ផ្តើមធ្វើការ និង ជះឥទ្ធិពលទៅលើឆន្ទៈរបស់មនុស្សឲ្យបែរទៅរកព្រះជាម្ចាស់ (គម្ពីរភីលីព ២:១៣) ។ អស់អ្នកណាដែលបែរត្រឡប់ទៅរកទ្រង់វិញ នឹងមានសិទ្ធិក្លាយទៅជាបុត្ររបស់ព្រះជាម្ចាស់ (គម្ពីរយ៉ូហាន ១:១២)។

ក្នុងពេលដែលព្រះជាម្ចាស់ លាតសន្ធឹងព្រះគុណរបស់ទ្រង់ទៅដល់ពួកមនុស្សដែលបានធ្លាក់ចុះ និង ជួយឲ្យពួកគេទទួលព្រះគ្រិស្តជាព្រះសង្គ្រោះរបស់ពួកគេ ទ្រង់មិនបានបង្ខិតបង្ខំពួកគេឲ្យធ្វើយ៉ាងដូច្នោះឡើយ។ តាមរយៈសកម្មភាពនៃឆន្ទៈ មនុស្សអាចនឹងទទួលព្រះអំណោយទាន ហើយ អាចនឹងក្លាយជាបុត្ររបស់ព្រះជាម្ចាស់ ឬ ពួកគេអាចនឹងច្រានចោលព្រះអំណោយទាននោះ ហើយស្ថិតនៅក្នុង

ការថ្កោលទោស (វិនិច្ឆ័យទោស) របស់ព្រះជាម្ចាស់ដដែល។ ឆន្ទៈរបស់ពួកគេ គឺមានសេរីភាពក្នុងសម្រេចទៅលើបញ្ហាមួយនេះ។ នៅក្នុងដំណើរការនៃការសម្រេចនោះ មានការចូលរួមទាំងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និង ឆន្ទៈរបស់មនុស្ស (គម្ពីរទីតុស ២:១១-១២ គម្ពីរយ៉ូហាន ៧:១៧)។

# លំហាត់អនុវត្តន៍

១០ ចូរផ្គូផ្គង ខគម្ពីរ (ខាងស្ដាំ) ទៅជាមួយនឹងប្រយោគ (ខាងឆ្វេង)។

........ក) ព្រះគុណព្រះអង្គ ...អប់រំយើងអោយលះបង់ចិត្ត ដែលមិនចេះគោរពប្រណិប័តន៍ព្រះជាម្ចាស់ចោល អោយលះបង់សេចក្ដីប៉ងប្រាថ្នាខាងលោកីយ៍

........ខ) ដ្បិតព្រះជាម្ចាស់ទេតើ ដែលធ្វើអោយបងប្អូនមានទាំងបំណង មានទាំងសមត្ថភាពអាចនឹងប្រព្រឹត្ត..។

........គ) អ្នកដែលចង់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ មុខជាដឹងថា សេចក្ដីដែលខ្ញុំបង្រៀននេះ មកពីព្រះអង្គ ឬមកពីខ្ញុំផ្ទាល់មិនខាន។

........ឃ) ខ្ញុំមានឆន្ទៈនឹងធ្វើអំពើល្អ តែខ្ញុំគ្មានសមត្ថភាពនឹងប្រព្រឹត្តអំពើល្អបានឡើយ។

១) គម្ពីរយ៉ូហាន ៧:១៧
២) គម្ពីរភីលីព ២:១៣
៣) គម្ពីរទីតុស២:១១-១២
៤) គម្ពីររ៉ូម៧:១៨

១១ នៅក្នុងដំណើរការដែលនាំទៅរកការធ្វើសកម្មភាព ឬ ការសម្រេចចិត្ត យើងឃើញថា ញាណសតិ ឬ ឫទ្ធានុភាពខាងឯវិចារណញ្ញាណរបស់មនុស្សជាតិទាំងអស់ចូលរួមក្នុងការនោះ។ ចូរបំពេញបង្គ្រប់ប្រយោគខាងក្រោម ដើម្បីធ្វើការបកស្រាយអំពីដំណើរការនោះ។

ក) សតិបញ្ញា

ខ) អារម្មណ៍

គ) មនសិការ

ឃ) ឆន្ទៈ

ស្របពេលដែលញាណសតិខាងឯវិចារណញ្ញាណរបស់យើង បានចូលរួមនៅក្នុងការធ្វើការសម្រេចចិត្ត ព្រះវិញ្ញាណដ៏វិសុទ្ធបញ្ចេញឥទ្ធិពលវិជ្ជមានដើម្បីជាប្រយោជន៍ ដរាបណាយើងនៅរក្សាផ្ចត់គំនិតរបស់យើងលើអ្វីដែលព្រះវិញ្ញាណសព្វព្រះហឫទ័យ (សូមមើលគម្ពីររ៉ូម ៨:៥-៩,១២-១៤) ហើយទ្រង់ធ្វើការនៅក្នុងយើងដើម្បីនាំមកឲ្យយើងនូវបំណងចិត្តមួយសម្រាប់បំណងព្រះហឫទ័យរបស់ទ្រង់ (គម្ពីរភីលីព ២:១៣) ។ ការរៀនរស់នៅក្នុងព្រះវិញ្ញាណ និង រក្សាជំហានរបស់យើងនៅក្នុងព្រះវិញ្ញាណ ជាការតំណាងឲ្យការរីកលូតលាស់ខាងឯបទពិសោធន៍ នៅក្នុងជីវិតរបស់យើងម្នាក់ៗ នៅពេលដែលយើងធ្វើដំណើរឡើងម្ដងបន្តិចៗ ឆ្ពោះទៅភាពពេញវ័យរបស់គ្រិស្ដបរិស័ទ (គម្ពីរកាឡាទី ៥:១៦-១៨, ២៥)។

# គ. ភាពអមតៈរបស់មនុស្សជាតិ

**វត្ថុបំណងទី៥.** *បកស្រាយគំនិតអំពីភាពអមតៈ និង អ្វីដែលកើតឡើងចំពោះមនុស្ស បន្ទាប់ពីគេបានស្លាប់ខាងឯរូបកាយហើយ។*

តើមានរឿងអ្វីកើតឡើងទៅលើមនុស្សក្រោយពេលស្លាប់ទៅ? មានរឿងជាច្រើនដែលយើងមិនដឹងអំពីជីវិតបន្ទាប់ស្លាប់ហើយ ប៉ុន្តែព្រះគម្ពីរបានបង្រៀនយើង រឿងមួយចំនួនដែលបង្ហាញថាមានជីវិតបន្ទាប់ពីការស្លាប់ទៅ។

ការស្លាប់ខាងឯរូបកាយ គឺជាអ្វីដែលកើតឡើងនៅពេលណាដែលរូបកាយឈប់បំពេញតួនាទីបន្តទៅទៀត។ រូបកាយក៏ត្រូវរលួយ និង ត្រឡប់ទៅជាធូលីដីវិញ (សូមមើលគម្ពីរលោកុប្បត្តិ ៣:១៩) ប៉ុន្តែទិដ្ឋភាពអរូបីរបស់មនុស្សជាតិ ដែលព្រះគម្ពីរហៅថា ព្រលឹង ឬ វិញ្ញាណនោះ នៅបន្តមានវត្តមានតទៅទៀត។ បទគម្ពីរជាច្រើនបានបញ្ជាក់អំពីការនេះ៖

> ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់អោយអ្នកដឹងច្បាស់ថា ថ្ងៃនេះអ្នកបានទៅនៅស្ថានបរមសុខ*ជាមួយខ្ញុំ»។ (គម្ពីរលូកា ២៣:៤៣)។
>
> យើងចូលចិត្តឃ្លាតឆ្ងាយពីរូបកាយនេះ ហើយទៅនៅជិតព្រះអម្ចាស់ប្រសើរជាង។ (គម្ពីរ២កូរិនថូស ៥:៨)។
>
> បើខ្ញុំរស់ក្នុងលោកនេះតទៅទៀត ធ្វើអោយកិច្ចការរបស់ខ្ញុំបានផល ខ្ញុំមិនដឹងជាជ្រើសរើសយកផ្លូវណាឡើយ!។ ចិត្តខ្ញុំរារែកទាំងសងខាង គឺម្យ៉ាងខ្ញុំប៉ងប្រាថ្នាចង់លាចាកលោកនេះ ទៅនៅជាមួយព្រះគ្រិស្តនោះប្រសើរជាងឆ្ងាយណាស់។ (គម្ពីរភីលីព ១:២២-២៣)។
>
> អ្នកណាស្ដាប់សេចក្ដីដែលខ្ញុំនិយាយហើយជឿលើព្រះអង្គដែលបានចាត់ខ្ញុំអោយមក អ្នកនោះមានជីវិតអស់កល្បជានិច្ច គេមិនត្រូវទទួលទោសឡើយ គឺបានឆ្លងផុតពីសេចក្ដីស្លាប់ទៅរកជីវិត។ (គម្ពីរយ៉ូហាន ៥:២៤)។

សេចក្ដីស្លាប់ខាងឯរូបកាយរបស់មនុស្សជាតិ គឺជាទិដ្ឋភាពមួយនៃបណ្ដាសា ដែលបានមកពីនៅពេលដែលលោកអដាំប្រព្រឹត្តិអំពើបាប៖ "អ្នកកើតពីធូលីដី អ្នកត្រូវតែត្រឡប់ទៅជាធូលីដីវិញ" (គម្ពីរលោកុប្បត្តិ ៣:១៩)។ នៅពេលស្លាប់ គ្រិស្តបរិស័ទលែងមានវត្តមានជាភាវៈរូបី ឬ អរូបីពេញលេញទៀតហើយ ពួកគេមានព្រះពរនៃសេចក្ដីសង្ឃឹមអំពីការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ត នៅពេលនោះពួកគេនឹងទទួលបានរូបកាយដែលពេញដោយសិរីរុងរឿង។ តាមរយៈការសុគត និង តាមរយៈការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ ទ្រង់បានធានានូវការប្រោសឲ្យរស់ពីស្លាប់សម្រាប់ពួកយើងដែរ។ រឿងនេះមានបកស្រាយនៅក្នុងគម្ពីរ ១កូរិនថូស ១៥:៤២-៤៩៖

> ចំណែកមនុស្សស្លាប់ ដែលរស់ឡើងវិញ ក៏ដូច្នោះដែរ រូបកាយដែលគេកប់ក្នុងដីតែងតែរលួយ រីឯរូបកាយដែលរស់ឡើងវិញ មិនចេះរលួយទេ។ រូបកាយដែលគេកប់ក្នុងដី ជារូបកាយដ៏ថោកទាប រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយសិរីរុងរឿង រូបកាយដែលគេកប់ក្នុងដី ជារូបកាយដ៏ទន់ខ្សោយ រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយឫទ្ធានុភាព។ រូបកាយដែលគេកប់ក្នុងដីជារូបកាយធម្មជាតិ រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយព្រះវិញ្ញាណ។

ប្រសិនបើមានរូបកាយធម្មជាតិមែន រូបកាយប្រកបដោយវិញ្ញាណក៏មានដែរ។ ហេតុនេះហើយបានជាមានចែងទុកមកថា «មនុស្សទីមួយ គឺលោកអដាំបានទទួលជីវិត»។ រីឯលោកអដាំចុងក្រោយបង្អស់ បានទៅជាព្រះវិញ្ញាណដែលផ្ដល់ជីវិត។ .....យើងមានទ្រង់ទ្រាយដូចមនុស្សដែលមានលក្ខណៈជាដីយ៉ាងណា យើងក៏នឹងមានទ្រង់ទ្រាយ ដូចព្រះអង្គដែលគង់នៅស្ថានបរមសុខយ៉ាងនោះដែរ។

ផ្ទុយពីនេះ នៅពេលមនុស្សបាបដែលមិនបានលន់តួស្លាប់ទៅ ព្រលឹងរបស់ពួកគេនឹងបន្តស្ថិតនៅក្នុងស្ថានភាពមួយដែលមានស្មារតីដឹងខ្លួន នៅក្នុងកន្លែងដែលប្រកបដោយទុក្ខវេទនា ហៅថាឋាននរក ឬរណ្ដៅនរកវិញ។ យើងបានឃើញខ្លះៗអំពីការនេះ នៅក្នុងរឿងនិទានមួយរបស់ព្រះយេស៊ូ និយាយអំពីបុរសអ្នកមាន និង លោកឡាសារ (គម្ពីរលូកា ១៦:១៩-២៤) ។ នៅក្នុងឋាននរក បុរសអ្នកមានដែលព្រះយេស៊ូរៀបរាប់នោះ អាចគិត អាចចងចាំ និយាយ និង ទទួលអារម្មណ៍។ គាត់ក៏នៅរក្សាការដឹងខ្លួនរបស់គាត់ផងដែរ។

ដូច្នេះហើយ យើងឃើញថាមនុស្សគឺត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់ ឲ្យជាភាវៈអមតៈ។ នេះគឺជាសេចក្ដីសង្ឃឹមដែលប្រទានទៅឲ្យអស់អ្នកដែលបានទទួលយក កិច្ចការរំដោះបាបអំពីព្រះគ្រិស្ដ និងអ្នកដែលបម្រើ និងស្ដាប់បង្គាប់តាមទ្រង់។ នៅពេលដែលអ្នកជឿស្លាប់ទៅ ព្រលឹងរបស់ពួកគេ នឹងស្ថិតនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ភ្លាមៗតែម្ដង។ នៅក្នុងការយាងមកជាលើកទីពីររបស់ទ្រង់ រូបកាយដែលអាចស្លាប់របស់ពួកគេ នឹងត្រូវបានប្រោសឲ្យរស់ឡើងវិញ ហើយត្រូវបានផ្លាស់ប្រែទៅជារូបកាយដែលប្រកបដោយសិរីរុងរឿង (គម្ពីរ១កូរិនថូស ១៥:៥០-៥៧) ។ ថ្ងៃនោះនឹងពិតជាថ្ងៃដែលពេញដោយសិរីរុងរឿងមួយ! ទោះជាយ៉ាងណា អ្នកមិនជឿនឹងប្រឈមមុខនឹងការវិនិច្ឆ័យទោសអស់កល្បជានិច្ច និងទារុណកម្មដែលមកពីព្រះវត្តមានរបស់ព្រះអម្ចាស់ (សូមមើលគម្ពីរវិវរណៈ ២០:៧-១០)។

## លំហាត់អនុវត្តន៍

១២ ចូរឆ្លើយសំណួរខាងក្រោម ដាក់ក្នុងសៀវភៅកត់ត្រារបស់អ្នក ដោយផ្អែកលើការពិភាក្សាខាងលើ

ក) តើនឹងមានរឿងអ្វីកើតឡើង ចំពោះរូបកាយនៅពេលមនុស្សស្លាប់ទៅ?

ខ) តើមានរឿងអ្វីកើតឡើង ចំពោះព្រលឹង ឬ វិញ្ញាណនៅពេលមនុស្សស្លាប់ទៅ?

គ) តើនឹងមានរឿងអ្វីកើតឡើង សម្រាប់គ្រិស្ដបរិស័ទ នៅក្នុងការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ដ?

ឃ) តើវាសនាអស់កល្បជានិច្ចរបស់អ្នកដែលមិនទទួលស្គាល់ព្រះគ្រិស្ដ នឹងទៅជាយ៉ាងណា?

ង) ចូរបកស្រាយការលើកឡើងមួយនេះ៖ "មនុស្សគឺជាភាវៈអមតៈ"។

# ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើស។ ចូរគូសរង្វង់ជុំវិញអក្សរខាងមុខចម្លើយត្រឹមត្រូវ។

១ ទស្សនវិស័យរបស់ព្រះគម្ពីរអំពីការបង្កើតលោកអដាំ គឺថា

ក) លោកគ្រាន់តែជាភាវៈរស់មួយនៅក្នុងក្នុងចំណោមភាវៈរស់ជាច្រើនដែលព្រះជាម្ចាស បានបង្កើត នៅក្នុងពេលជាក់លាក់ណាមួយប៉ុណ្ណោះ។

ខ) លោកគឺជាស្នាព្រះហស្តពិសេសមានតែមួយ របស់ព្រះជាម្ចាស់ ដែលបានលើកឲ្យខ្ពស់ លើសភាវៈដទៃផ្សេងទៀត និង ទទួលបានព្រះពរពីព្រះជាម្ចាស់។

គ) លោកបានវិវត្តន៍ ក្នុងរយៈពេលមួយយ៉ាងយូរ ចាប់ផ្តើមពីទិដ្ឋភាពដែលទាបជាងគេនៅក្នុងស្នាព្រះហស្ត រហូតដល់គាត់អាចគ្រប់គ្រងលើស្នាព្រះហស្តទាំងនោះម្តងបន្តិចៗ។

២ នៅពេលដែលយើងនិយាយថា យើងត្រូវបានបង្កើតឡើងមកឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់ យើងចង់បានន័យថា យើង

ក) ដូចជាព្រះជាម្ចាស់បះបិទ គ្រប់ជ្រុងទាំងអស់។

ខ) ពេលនេះ គឺជាការចម្លងតាមព្រះជាម្ចាស់ដែលមានកម្រិត ហើយយើងនឹងក្លាយដូចជា ព្រះជាម្ចាស់គ្រប់យ៉ាង រួមជាមួយនឹងឫទ្ធានុភាព និង សិទ្ធិអំណាចគ្មានដែនកំណត់។

គ) ដូចនឹងព្រះជាម្ចាស់ត្រង់ បុគ្គលិកលក្ខណៈ សីលធម៌ និង ការដឹងពីសង្គម និង សមត្ថភាពក្នុងការគ្រប់គ្រង។

៣ មនុស្សគឺត្រូវបានបង្កើតឡើងពី

ក) ទិដ្ឋភាពខាងរូបី និង អរូបី។

ខ) រូបកាយមួយដែលសឹករិចរឹល និង រលួយស្អុយបន្ទាប់ពីស្លាប់ទៅ និង ព្រលឹងដែលស្លាប់ទៅ រហូតដល់ពេលមួយដែលវានឹងត្រូវបានប្រោសឲ្យរស់ឡើងវិញ នៅគ្រានៃការវិនិច្ឆ័យចុងក្រោយបំផុត។

គ) រូបកាយមួយដែលអាក្រក់ ហើយមានទិដ្ឋភាពអរូបីដែលល្អ។

៤. ទិដ្ឋភាពអរូបីរបស់មនុស្សជាតិ ជាគោលការណ៍សំខាន់នៃជីវិតជីវសាស្ត្រ ត្រូវបានអ្នកប្រាជ្ញខ្លះចាត់ទុកជា

ក) រូបកាយ

ខ) ព្រលឹង

គ) វិញ្ញាណ

ឃ) ដង្ហើមនៃជីវិត

៥ *ព្រលឹង វិញ្ញាណ ដង្ហើមនៃជីវិត* និង *មនសិការ* គឺជាពាក្យដែលបានប្រើនៅក្នុងព្រះគម្ពីរ ដើម្បីនិយាយសំដៅទៅលើ..............................របស់មនុស្សជាតិ។

ក) ជីវិតរូបី

ខ) ជីវិតអរូបី

គ) បុគ្គលិកលក្ខណៈ

ឃ) រូបកាយ។

៦ តើប្រយោគណាមួយនៅខាងក្រោមនេះ ត្រឹមត្រូវទាក់ទងនឹងធាតុផ្សំរបស់មនុស្សក្នុងនាមជាភាវៈដែលមានគំនិត?

ក) សតិបញ្ញាដែលជួយឲ្យបុគ្គលមួយរូបអាចយល់ដឹង និង មានហេតុផល។

ខ) អារម្មណ៍ ដែលជួយឲ្យបុគ្គលមួយរូបអាច ទទួលអារម្មណ៍ដឹង និង ទទួលឥទ្ធិពលពីអ្វីដែលអ្នកនោះដឹង។

គ) សកម្មភាព ឬ ឥរិយាបថដែលថ្លឹងថ្លែងដោយមនសិការ ដែលផ្អែកលើខ្នាតគំរូត្រូវ ឬ ខុស។

ឃ) ឆន្ទៈគឺជាញាណសតិដែលជួយឲ្យមនុស្សម្នាក់ ជ្រើសរើស និង ធ្វើសកម្មភាព។

៧ នៅពេលដែលគេយល់ពីបញ្ហាមួយបានច្បាស់ ជំហានទីមួយ

ក) ឆន្ទៈជាអ្នកសម្រេចលើបញ្ហានោះភ្លាមៗ។

ខ) សតិបញ្ញាចង្អុលបង្ហាញពីការល្អ និង អាក្រក់ដូចបានប្រៀបធៀបទៅនឹងខ្នាតគំរូមួយ។

គ) អារម្មណ៍ប្រាប់ទៅកាន់មនុស្សម្នាក់ឲ្យធ្វើសកម្មភាព តាមរបៀបណាមួយ ឬ តាមរបៀបផ្សេងទៀត។

ឃ) មនសិការធ្វើឲ្យមានការអាម៉ាស់ និង ការស្ដាយក្រោយ។

៨ នៅក្នុងដំណើរការនៃការធ្វើការសម្រេចចិត្ត ដំបូងបំផុតបុគ្គលម្នាក់ត្រូវ

ក) មានការយល់ដឹងអំពីការពិតនៃបញ្ហាដែលចោទឡើង។

ខ) សម្រេចចិត្ត ថាគួរធ្វើអ្វីមួយ ដោយយោងទៅតាមខ្នាតគំរូនៃសង្គមរបស់គេ។

គ) ពិចារណាអំពីអារម្មណ៍របស់ខ្លួន និង ផលវិបាកនៃការសម្រេចចិត្តរបស់គេ។

៩ មនសិការគឺជាធាតុផ្សំដែល

ក) សុំឲ្យមានការសម្រេចចិត្ត ដោយផ្អែកលើបំណងចិត្តរបស់បុគ្គលម្នាក់។

ខ) ថ្លឹងថ្លែងសកម្មភាព ផ្ទុយនឹងខ្នាតគំរូនៃចរិយាមារយាទរបស់បុគ្គលម្នាក់។

គ) ធ្វើការសម្រេចចិត្ត ដើម្បីបញ្ចេញសកម្មភាព

ឃ) ជ្រើសរើសរបៀបធ្វើសកម្មភាព។

១០ ឆន្ទៈរបស់យើងបំពេញតួនាទី ដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រោះ

ក) បំណងចិត្តចង់ធ្វើការល្អ។

ខ) មនសិការរបស់យើង ដែលបង្ហាញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មកកាន់យើង។

គ) ព្រះគុណរបស់ព្រះជាម្ចាស់ដែលនាំមកនូវការសង្គ្រោះ និង ការជួយឲ្យស្តាប់បង្គាប់ទ្រង់។

ឃ) សេចក្តីកោតខ្លាចការថ្កោលទោស ឬ ការវិនិច្ឆ័យទោស របស់ព្រះជាម្ចាស់។

១១ តើចម្លើយណាមួយខាងក្រោមនេះ ជាចម្លើយត្រឹមត្រូវទាក់ទងនឹងភាពអមតៈរបស់យើង?

ក) រូបកាយ និង ព្រលឹងរបស់យើង គឺអមតៈ នៅក្នុងស្ថានភាពដូចបច្ចុប្បន្ននេះ។

ខ) ខ្លួនប្រាណដែលមានរូបរបស់យើង នឹង រលួយស្អុយ និង ស្លាប់ទៅ ប៉ុន្តែព្រលឹងរបស់យើងនឹងរស់នៅជាដរាប នៅក្នុងសភាពដែលមានសុខសន្តិភាពដ៏ល្អឥតខ្ចោះ។

គ) ខ្លួនប្រាណរបស់យើងនឹងស្លាប់ ព្រលឹង ឬ វិញ្ញាណរបស់អ្នកជឿនឹងបាននៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ភ្លាមៗ ហើយនៅក្នុងពេលដែលព្រះយេស៊ូយាងមកជាលើកទីពីរ ពួកគេនឹងទទួលបាននូវរូបកាយការប្រោសឲ្យមានជីវិត ប្រកបដោយសិរីរុងរឿង ចំណែកអ្នកមិនជឿ នឹងត្រូវឆ្លងកាត់ការកាត់ទោស នៅក្នុងនរគអស់កល្បជានិច្ច។

# ចម្លើយលំហាត់អនុវត្តន៍

១ ក) ព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាងរបស់ព្រះអង្គ។
ខ) ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និង មនុស្សស្រី ឲ្យមានលក្ខណៈដូចជាទ្រង់។
គ) ព្រះជាម្ចាស់បានបង្កើតមនុស្សឡើងមក។
ឃ) ព្រះជាម្ចាស់បានបង្កើតមនុស្សលោកមកជាតំណាងរបស់ព្រះអង្គ។
ង) ព្រះជាម្ចាស់បង្កើតមនុស្សនៅលើផែនដីនេះ។
ច) ព្រះអង្គបានបង្កើតយើងមក។
ឆ) មនុស្សដែលព្រះអង្គបានបង្កើតមក អោយមានលក្ខណៈដូចព្រះអង្គ។

៧ ធាតុផ្សំខាងឯសតិបញ្ញា ឆន្ទៈ ធាតុផ្សំខាងឯអារម្មណ៍ និង មនសិការ។

២ ខ) មានតែមនុស្សប៉ុណ្ណោះដែលបានទទួលជីវិត មកពីការផ្លុំខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់។
គ) មនុស្សទទួលបានអំណាចគ្រប់គ្រងលើជីវិតរុក្ខជាតិ និង សត្វ។
ឃ) មនុស្សត្រូវបានបង្កើតមកឲ្យមានសណ្ឋានដូចជាព្រះអាទិកររបស់ពួកគេ។
ង) មនុស្សគឺខុសពី ភាវៈផ្សេងទៀតនៅលើផែនដី ហើយថែមទាំងខ្ពង់ខ្ពស់ជាងភាវៈទាំងនេះផង។

៨ ភាពអាម៉ាស់ ភាពស្តាយក្រោយ និង ភាពភ័យខ្លាច

៣ ក) និស្ស័យខាងឯសង្គម
ខ) លក្ខណៈដូចខាងឯសីលធម៌
គ) និស្ស័យដែលប្រកបដោយវិចារណញ្ញាណ
ឃ) ភាពយល់ច្បាស់ពីខ្លួនឯង
ង) បុគ្គលិកលក្ខណៈ
ច) សមត្ថភាពគ្រប់គ្រង
ឆ) លក្ខណៈដូចគ្នាខាងឯសីលធម៌

៩ ក) ត្រូវ
ខ) ខុស
គ) ត្រូវ
ឃ) ខុស
ង) ខុស (ផ្ទុយទៅវិញ មនសិការរបស់មនុស្សគឺសាងឡើងដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដូចដែលត្រូវបានបកស្រាយដោយព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ។
ច) ត្រូវ
ឆ) ខុស

៤ ក) ១) គម្ពីរលោកុប្បត្តិ ១:២៧,៣១ និង
៤) គម្ពីរទំនុកតម្កើង ១៣៩:១៣-១៦
ខ) ៥) គម្ពីរហេប្រឺ ២:១៤-១៥,១៧-១៨
គ) ៩) គម្ពីរ១កូរិនថូស ១២:១២-២៧
ឃ) ៣) គម្ពីរ១កូរិនថូស ៦:១៥,១៩-២០
ង) ៨) គម្ពីររ៉ូម ៨:២៣ និង ៦) គម្ពីរ១កូរិនថូស ៦:១៤
ច) ២) គម្ពីររ៉ូម ១២:១
ឆ) ៧) គម្ពីរភីលីព ៣:២០-២១

១០ ក) ៣) គម្ពីរទីតុស ២:១១-១២
ខ) ២) គម្ពីរភីលីព ២:១៣
គ) ១) គម្ពីរយ៉ូហាន ៧:១៧
ឃ) ៤) គម្ពីររ៉ូម ៧:១៨

៥ នៅក្នុងព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន(២០០៥) បានប្រើពាក្យខាងក្រោមនេះ៖
ក) ខ្យល់ដង្ហើមជីវិត (ទិដ្ឋភាពមួយ)(ពគប១៩៥៤)
ខ) ព្រលឹង (ទិដ្ឋភាពមួយ) (ពគប១៩៥៤)
គ) វិញ្ញាណ (ទិដ្ឋភាពមួយ) (គខប២០០៥)
ឃ) ព្រលឹង និងវិញ្ញាណ (ទិដ្ឋភាពពីរ) (គខប២០០៥)
ង) ព្រលឹងនិងវិញ្ញាណ (ទិដ្ឋភាពពីរ) (គខប២០០៥)

១១ ចម្លើយអ្នករបស់គួរតែស្រដៀងនឹងចម្លើយខាងក្រោមនេះ៖
ក) យល់ដឹងពីអ្វីដែលទាក់ទង ឬ អ្វីដែលត្រូវតែធ្វើការសម្រេចចិត្ត។
ខ) ជំរុញឲ្យមានសកម្មភាពមួយ ឬ សកម្មភាពមួយផ្សេងទៀតកើតឡើង។
គ) ថ្លឹងថ្លែងសកម្មភាពដែលបានគិតទុក ទាស់នឹងខ្នាតគំរូសីលធម៌របស់មនុស្សម្នាក់។
ឃ) សម្រេចបញ្ហា។

៦ ង) បទគម្ពីរបានថ្លែងអំពី ខ្លួនប្រាណ ព្រលឹង វិញ្ញាណ ដង្ហើមនៃជីវិត និង ពាក្យជាច្រើនផ្សេងទៀត ដើម្បីធ្វើការរៀបរាប់អំពីនិស្ស័យរបស់យើង ប៉ុន្តែមិនបានបង្ហាញឲ្យបានច្បាស់ៗ ថាតើយើងមាននិស្ស័យនូវទិដ្ឋភាពពីរ ឬក៏ទិដ្ឋភាពបី។

១២ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយខាងក្រោមនេះ៖

ក) វានឹងត្រូវស្អុយរលួយ និង ត្រឡប់ទៅជាធូលីដីវិញ។

ខ) គ្រិស្តបរិស័ទ នឹងបានទៅនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ភ្លាមៗ នាស្ថានបរមសុខ។ ចំណែកឯអ្នកមិនជឿវិញ ត្រូវរងទុក្ខវេទនាក្នុងឋាននរក។

គ) រូបកាយដែលអាចស្លាប់របស់ពួកគេ នឹងត្រូវបានប្រោសឲ្យមានជីវិតរស់ឡើងវិញ ហើយត្រូវបានផ្លាស់ប្តូរទៅជារូបកាយដែលដែលប្រកបដោយសិរីរុងរឿង។

ឃ) ការវិនិច្ឆ័យទោសដ៏អស់កល្បជានិច្ច និង ការថ្កោលទោស ឲ្យនៅដាច់ឆ្ងាយពីព្រះវត្តមានរបស់ព្រះជាម្ចាស់។

ង) មនុស្សត្រូវបានព្រះជាម្ចាស់បង្កើតឡើងមក ឲ្យមានជីវិតរូបី និង អរូបី ដែលព្រលឹង និងវិញ្ញាណរបស់ពួកគេ នឹងមិនអាចស្លាប់ឡើយ។ ពួកគេនឹងមានវត្តមានជារៀងរហូត ទាំងនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ ឬ នៅក្នុងឋាននរកជាកន្លែងដែលមានការថ្កោលទោសអស់កល្បជានិច្ច។